# សម្ភាសន៍ជាមួយឈ្មោះ ចាន់ ស៊ាន ហៅ សាម ភេទប្រុស អាយុ៦៨ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហមៈ “អនុសេនាធំ”
## ស្រុកកំណើតនៅភូមិស្រែចែង ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត
## សព្វថ្ងៃនៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ
## ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ និង ឡុង ដានី
## ០១:០៦:៤៦“ភាគទី១”០០:៥៥:០១“ភាគទី២”
## ៤៨ទំព័រ

វណ្ណៈ ជាដំបូងខ្ញុំចង់ណែនាំខ្លួនថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំឈ្មោះ សុខ វណ្ណៈ ហើយខាងនេះឈ្មោះ ឡុង ដានី ធ្វើការជាមួយគ្នា ហើយខ្ញុំមកស្រុកត្រពាំង ប្រាសាទនេះគឺចង់ដឹងរឿងរ៉ាវដែលទាក់ទង សម័យក្រោយ៧៩និងប្រវត្តិរបស់អ៊ុំខ្លះៗថា ហេតុអីបានជាអ៊ុំមកដល់នេះ ចឹងខ្ញុំសុំការអនុញ្ញាតិពីអ៊ុំ តើអាចឲ្យខាងខ្ញុំផ្ដល់បទសំភាសបានទេ?

ស៊ាន់ៈ បាទ!ចុះមានអី មានហាមឃាត់អីទេ។

វណ្ណៈ បាទ!ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ អ៊ុំ អ៊ុំឈ្មោះដែរ?

ស៊ាន់ៈ ខ្ញុំឈ្មោះ ចាន់ ស៊ាន់។

វណ្ណៈ អ៊ុំមានឈ្មោះ ហៅក្រៅទេ?

ស៊ាន់ៈ ហៅក្រៅឈ្មោះ ចាន់ សាម។

វណ្ណៈ អ៊ុំអាយុប៉ុន្មានហើយ?

ស៊ាន់ៈ ខ្ញុំអាយុវាចាំមិនបានដែរ ខ្ញុំម៉ែឪវង្វេងដែលតែគាត់ថាខ្ញុំអាយុ៦៨ឆ្នាំហើយ។

វណ្ណៈ អ៊ុំកើតឆ្នាំខ្មែរឆ្នាំអីដែរ?

ស៊ាន់ៈ ខ្ញុំវាពិបាកចាំទៀតខ្ញុំអត់ចាំឆ្នាំទេ ការពិតខ្ញុំចាំតែឆ្នាំ១៩៥៥ អះ!កើត៤៥ ប៉ុន្មានហើយអាយុ។

វណ្ណៈ ៤៥បើយើងជាលេខ៦៨។

ស៊ាន់ៈ ចឹងត្រូវហើយ ខ្ញុំឆ្នាំក្រោយ៦៩ហើយ។

វណ្ណៈ ហើយគ្រួសារអ៊ុំមុនគាត់ឈ្មោះ អីដែរ?

ស៊ាន់ៈ គាត់ឈ្មោះ ជិម ណៃ ហៅ គួយ។

វណ្ណៈ អ៊ុំជាមួយគ្រួសារអ៊ុំមុនមានកូនចៅប៉ុន្មាននាក់ដែរ?

សាន់៖ កូនខ្ញុំមាន៦នាក់ ។

វណ្ណៈ ៦នាក់ហ្នឹងមានស្រីប៉ុន្មានដែរ?

សាន់៖ មានស្រីតែមួយទេ អូស!ស្រីមានពីរប្រុស្បី កូនពៅមួយនៅរាល់នៅរៀន ។

វណ្ណៈ គាត់រៀនដល់ណាហើយ?

សាន់៖ រៀនជាប់បាក់ឌុបហើយ តែវាថាដូចជាអត់ចង់រៀន វាមិនទាន់ទៅណាផង បាក់ឌុបក៏ជាប់ ឌីប្លូមក៏ជាប់ ។

វណ្ណៈ គាត់អត់មានគិតថា ចង់ទៅរៀនមហាវិទ្យាល័យអីទេ?

សាន់៖ វាគិតថា ចង់ទៅរៀនមហាវិទ្យាល័យដែលតែវាថាចាំមើលសិន ។

វណ្ណៈ ចឹងកូនអ៊ីទាំង៦នាក់ហ្នឹងមានទៅរៀននៅមហាវិទ្យាល័យប៉ុន្មាន?

សាន់៖ ទេ អត់មានទេអូន អត់បានរៀនទេ ពីសម័យនោះមិនរៀនទេ ព្រោះកូនខ្ញុំកើតសម័យ មុនខ្មែរក្រហមសម័យសង្គមរាស្ត្រនិយម ។

វណ្ណៈ ចឹងសព្វថ្ងៃគាត់ទាំង៦នាក់ហ្នឹងនៅរស់ទាំងអស់ដែរ?

សាន់៖ រស់ទាំងអស់ ។

វណ្ណៈ ហើយគាត់មានគ្រួសារប៉ុន្មានហើយ?

សាន់៖ មានគ្រួសារហើយនៅសល់តែពីរទេ អស់៤នៅសល់២ ។

វណ្ណៈ ចឹងនៅពីរនៅក្នុងបន្ទុក?

សាន់៖ នៅក្នុងបន្ទុកមួយវានៅធ្វើប៉េអ៊ឹមនៅអន្លង់វែង មួយទៀតនៅក្នុងបន្ទុកហ្នឹងនៅលីវ មួយប្រុសនេះស្រី ។

ដានី៖ ចឹងមួយធ្វើប៉េអ៊ឹម គាត់នៅលីវដែរ?

សាន់៖ បាទ!នៅលីវមិនទាន់យកប្រពន្ធទេ ។

ដានី៖ ហ៊ឺ!ប៉ុន្មាននាក់ទៀតគាត់មានគ្រួសារគាត់នៅនេះដែលឬយ៉ាងម៉េច?

សាន់៖ នៅអន្លង់វែង១នៅនេះ២ ចាំមើលខ្ញុំជិរាប នៅអន្លង់វែងមួយប្អូន នៅជាប់ខ្ញុំនេះបងគេ កំបុតជើងម្ខាងពិការជើងហើយមួយទៀតនៅខាងត្បូងខ្ញុំហ្នឹងវាធ្វើប៉ូលីសវាឲ្យឈ្មោះទៅមេ យកលុយទៅវារត់ឡាន រកស៊ីដឹកជញ្ជូនចឹងណាស់ ហើយមួយទៀតទៅនៅជាមួយ ឈ្មោះ ស្រី ឌឹកកាន់ខាងគ្រឿងចក្រហ្នឹងប្រុសដែលទើបយកប្រពន្ធទេ ។

វណ្ណៈ គាត់នៅព្រះវិហារចឹង?

សាន់៖ នៅព្រះវិហារ ។

វណ្ណៈ ចឹងគ្រួសារអ៊ីក្រោយមានកូនចៅទេ?

សាន់៖ នេះ មានមួយហ្នឹង គាត់មានកូនមួយនៅកំពង់ចាម កូនប្រុស ។

វណ្ណៈ គាត់មានឈ្មោះ អីដែរ?

សាន់៖ គាត់ឈ្មោះ ឈឹម មួយខេង គាត់នៅកំពង់ធំ នៅឃុំទ្រា ភូមិរំលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ដានី៖ ខ្ញុំអ្នកកំពង់ចាម ។

សាន់៖ គាត់ក៏មានប្តីខេត្តកំពង់ចាម តែគាត់លែងលះគ្នាទៅ ប្តីគេយកប្រពន្ធមួយទៀត ស្ទឹងហួស រំលងទៅតាំងគោក ។

វណ្ណៈ ឪពុកអ៊ំឈ្មោះអីដែរ?

សាន់៖ ឈ្មោះ ប៉ិញ សុខ ។

វណ្ណៈ ម្តាយ?

សាន់៖ ជា ដួង ។

វណ្ណៈ អ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់?

សាន់៖ ខ្ញុំបើនិយាយពីបងប្អូនមានច្រើនណាស់ ស្លាប់អស់ហើយខ្ញុំមិនចង់និយាយទាំងអស់ទេ ស្លាប់ដោយជំងឺហ្នឹងមុនហ្នឹងពីរទៅ ស្លាប់ក្នុងអតីតខ្មែរក្រហមហ្នឹងមើលអស់បីនាក់ហើយ ឥឡូវនៅសល់តែ៦ទេ បើងមាន១០នាក់ទាំងស្លាប់ ។

វណ្ណៈ បើង១០នាក់ហ្នឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាន?

សាន់៖ ១០ហ្នឹងមានស្រីតែ២ទេ តែស្លាប់អស់ហើយនៅសល់១ នៅសល់ប្អូនស្រីមួយនៅរាល់ថ្ងៃ ។

វណ្ណៈ បើងខ្ញុំចង់ស្គាល់គាត់ថា បងទី១ឈ្មោះអីដែរ?

សាន់៖ ទី១ គឺខ្ញុំតែម្តង ។

វណ្ណៈ ទី២?

សាន់៖ ទី២ឈ្មោះ ចាន់ រស់ នៅស្រុក ។

វណ្ណៈ នៅស្រុកកំណើត?

សាន់៖ បាទ! នៅស្រុកកំណើតទាំងអស់ ។

វណ្ណៈ ទី៣?

សាន់៖ ទី៣ឈ្មោះ ចាន់ សេម នៅស្រុកដែរ នៅនរាយ ។

វណ្ណៈ ទី៤?

សាន់៖ ទី៤ឈ្មោះ ចាន់ រឿន ទី៥ឈ្មោះ ចាន់ មុំ ដែលនៅរាល់ថ្ងៃហ្នឹង ទី៦ឈ្មោះ ចាន់ សំណាងនៅឈូក នៅផ្សារឈូក នៅសល់តែ៦នាក់ហ្នឹង ។

វណ្ណៈ ចឹងស្រុកកំណើតអ៊ំនៅភូមិអីដែរ?

ស៊ាន់ៈ ខ្ញុំស្រុកកំណើតនៅភូមិស្រែចែង ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត តែឥឡូវដូរអស់ហើយ ។

ដានីៈ ឥឡូវគេដាក់ជុំគិរីវិញ?

ស៊ាន់ៈ បាទ!ឥឡូវដាក់ជុំគិរីវិញត្រូវហើយ ។

វណ្ណៈ ចឹងឃុំ?

ស៊ាន់ៈ ឃុំពីដើមគេដាក់ត្រពាំងរាំង ឥឡូវគេដាក់ឃុំស្រែចែង ស្រុកជុំគិរី ។

ដានីៈ ខ្ញុំនៅហ្នឹងខ្ញុំស្គាល់តា ដែន អាចារ្យ?

ស៊ាន់ៈ អាចារ្យ ដែន ហ្នឹងខ្ញុំស្គាល់ដែលនៅជិតវត្ត ។

ដានីៈ ខ្ញុំធ្លាប់ទៅសំភាសគាត់តាំងពីឆ្នាំ២០០២-២០០៣ ។

ស៊ាន់ៈ តែខ្ញុំមកយូរហើយដាច់ពីស្រុកពីគេពីឯង ។

វណ្ណៈ ចឹងសព្វថ្ងៃនៅភូមិនេះគេហៅភូមិអីដែលសព្វថ្ងៃ?

ស៊ាន់ៈ សព្វថ្ងៃគេហៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ ចឹងភូមិត្រពាំងប្រាសាទធំនាស់ តាំងពីសាលាស្រុករហូតដល់នេះ?

ស៊ាន់ៈ បាទ ។

វណ្ណៈ ផ្សារទាំងមូលហ្នឹងភូមិត្រពាំងប្រាសាទ?

ស៊ាន់ៈ បាទ!ភូមិត្រពាំងប្រាសាទទាំងអស់ ។

វណ្ណៈ ចឹងអ៊ំកាលពីតូចបានរៀនសូត្រដល់ណាហើយមានបានបួសរៀនទេ?

ស៊ាន់ៈ កាលពីតូចខ្ញុំរៀនដល់ថ្នាក់ទី៧ ខ្ញុំនៅភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ។

វណ្ណៈ សាលាបឋមសិក្សា?

ស៊ាន់ៈ សាលាបឋមសិក្សាមាំងគល់មានល័ក្ខគេហៅត្រពាំងគល់ ។

ដានីៈ ចឹងអ៊ំស្គាល់ តា ម៉ុក ដែលចឹង?

ស៊ាន់ៈ ខ្ញុំថីមិនស្គាល់តា ម៉ុក គាត់អ្នកចាស់ទុំ អាចារ្យបាលីនៅស្រុកនោះ ពីដើមខ្ញុំនៅក្មេងៗ ទៅរៀនគាត់នៅខាងត្រពាំងធំ ខ្ញុំរៀននៅត្រពាំងគល់ ឆ្ងាយពីគ្នាប្រហែលជាពីរទៅបីគីឡូ ។

វណ្ណៈ ចឹងអ៊ំបន្ទាប់ពីបានរៀនចប់មានបានបួសអីទេ?

ស៊ាន់ៈ អត់ទេ ។

វណ្ណៈ អ៊ំឈប់រៀននៅឆ្នាំណាដែរ?

ស៊ាន់៖ នៅឆ្នាំ១៩៦១ ។

វណ្ណៈ ហេតុអីបានជាអ៊ឹឈប់រៀន?

ស៊ាន់៖ បេះរឿងឈប់រៀនហ្នឹងវាបេះ ឪពុកម្ដាយទេ មិនមែនខ្ញុំចង់ឈប់រៀនទេ ឪពុកម្ដាយពីដើម គាត់នៅជនបទ ដល់ខ្ញុំមករស់នៅជាមួយលោក លោកចិញ្ចឹមជាឪពុកធម៌អីចឹងដល់ឪពុក ធម៌ខ្ញុំ ស្លាប់ទៅខ្ញុំសុំម្ដាយរៀនបន្តទេ គាត់ថាយើងមានបានធ្វើអីទេ អ្នកស្រែនោះធ្វើស្រែ ទៅកូនរក ប្រពន្ធឲ្យខ្ញុំ ចុះពីដើមយើងតាមម៉ែឪយើងរកប្រពន្ធទៅ ចែកស្រែចែក ភ្ជឹគិធ្វើស្រែ ។

វណ្ណៈ ចឹងអ៊ឹរៀបការឆ្នាំណា?

ស៊ាន់៖ ខ្ញុំការប្រហែលជាឆ្នាំ៦៣-៦៤អីហ្នឹង ខ្ញុំមិនចាំភ្លេចអស់ហើយអូនអើយយូរហើយ ។

វណ្ណៈ កាលហ្នឹងអ៊ឹមានអាយុប៉ុន្មានហើយ?

ស៊ាន់៖ កាលហ្នឹងអាយុ២១ហើយ ។

វណ្ណៈ ចឹងពេលអ៊ឹការហើយអ៊ឹធ្វើស្រែចម្ការ?

ស៊ាន់៖ ធ្វើស្រែចម្ការរកស៊ីជួញដូរដូចគេចឹង ។

វណ្ណៈ នៅស្រែចែងហ្នឹង?

ស៊ាន់៖ នៅស្រែចែង ជួញមាន់ ជួញជ្រូក ជួញអីហើយធ្វើស្រែចឹងទៅណាស់ ។

វណ្ណៈ ចឹងរហូតដល់មានចលនារដ្ឋប្រហារឆ្នាំ១៩៧០ តើនៅខាងស្រុករបស់អ៊ឹហ្នឹង តើមានចលនា អីកើតឡើងខ្លះ?

ស៊ាន់៖ កាលនោះខ្ញុំឮសូរថាខ្មែរក្រហមៗតែខ្ញុំមិនបានដឹងថា ពីណាជាខ្មែរក្រហម វាមានចលនាកាល នោះមាននៅត្រង់អូរកំបុតហ្នឹងមានសក្ដិ៣មួយ អះ!សក្ដិ១ឈ្មោះ សុន នោះ គាត់នៅដំណាក់ ដ្អឹកហ្នឹងណាស់ ចឹងគេរកចាប់ទាហាន ការរដ្ឋប្រហារជំនាន់ លន់ នល់ នោះដល់ចឹងស្រុកខ្ញុំ ខ្លះ គេទៅធ្វើទាហាន លន់ នល់ ទៅ ខ្ញុំមិនទាន់ទៅណាទេ ដល់គេចាប់ប្រជិតប្រជីងចឹងទៅហើយ វាមានបញ្ហាឪពុកធំខ្ញុំគាត់ធ្វើ«សេអ៊ីអា» ហើយតាបងខ្ញុំ ហ្នឹងក៏គាត់ធ្វើជា«សេអ៊ីអា»ដែរ ។

វណ្ណៈ «សេអ៊ីអា»ខាងណា?

ស៊ាន់៖ សេអ៊ីអាខាងអាមេរិច គាត់ត្រូវជាមួយប៉ូលីសប៉េអ៊ឹមអីចឹង ហើយខ្ញុំមិនបានដឹងទេ ដល់ចឹង បដិវត្តហ្នឹងគេយកទៅកំទិចដល់កំទិចទៅគេស្រាវជ្រាវដល់ខ្ញុំប្អូនតទៅទៀតក៏រត់ចេញពីស្រុកទៅ មកធ្វើជាទាហាន ។

វណ្ណៈ ហ្នឹងនៅក្នុងឆ្នាំណា?

ស៊ាន់៖ ឆ្នាំ៧១ ខ្ញុំរត់មកខាងកំពង់ស្ពឺ មកហាត់ទាហាន នៅត្រពាំងអណ្ដើកហ្នឹង ក៏អត់ដឹងអីទេ បេះតែ មកហើយ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧១ ពេលអ៊ីមកនៅខាងកំពង់ស្ពឺហ្នឹង អ៊ីមកចូលទាហានខាងខ្មែររំដោះ កាលនោះខ្មែរក្រហមគេហៅខ្មែររំដោះ?

ស៊ាន់ៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងមកចូលខាងខ្មែររំដោះឬមកចូលខាងទាហាន លន់ នល់?

ស៊ាន់ៈ អត់ទេ ខ្មែររំដោះ ។

វណ្ណៈ ចឹងកាលហ្នឹងចូលតាមការអំពាវនាវរបស់សម្តេចឬយ៉ាងម៉េច?

ស៊ាន់ៈ បាទ!ចូលព្រៃម៉ាគី តស៊ូដើម្បីរំដោះសម្តេចឪយកមកវិញ កាលនោះណា មកចឹងមែនអត់មានតាមខ្មែរក្រហមឬភាគីបក្សណាទេ ។

វណ្ណៈ ចឹងមានពីណាមកបង្ខិតបង្ខំអីទេ?

ស៊ាន់ៈ អត់មានទេ ។

វណ្ណៈ ចឹងកាលអ៊ីចូលដំបូងនៅខាងកំពង់ស្ពឺវិញទេ?

ស៊ាន់ៈ ខ្ញុំចូលមកខាងកំពង់ស្ពឺ ។

វណ្ណៈ ចឹងពេលអ៊ីមកដល់ហ្នឹងមេយោធាគ្រប់គ្រងគេឈ្មោះ អីហើយមុនពេលបានកាន់កាំភ្លើង តើមានការហាត់រៀនយ៉ាងម៉េចដែលអ៊ី?

ស៊ាន់ៈ ខ្ញុំមកដល់ដំបូងមិនបានហាត់ទេ មកក៏តាមមិត្តភក្តិ មិត្តភក្តិថា ឯងនៅក៏គេកំទេចចោល ដែលថាទៅធ្វើទាហានទៅ បើសាប់និងកាណុងកាំភ្លើងក៏ល្អដែលកុំឲ្យគេវាយយកដាក់គុកអី ចឹងខ្ញុំក៏ភ័យប្រពន្ធមិនប្រាប់ទេ ប្រាប់តែម៉ែ ថ្វាយបង្គំម៉ែមក ខ្ញុំនៅក៏សាប់ដែលម៉ែទៅក៏សាប់ដែលបំបាត់ខ្ញុំចោលមួយទៅ ក្នុងគ្រួសារយើងម៉ែមិនបាច់និយាយរឿងខ្ញុំទេ ខ្ញុំ មកហ្នឹងខ្ញុំមិនបានដឹងមេកើយអីទេ អា ផាន វាហៅខ្ញុំមកឥឡូវវានៅរាល់ថ្ងៃវាពិការជើងត្រឹមភ្លៅ វាចូលខាងយេស៊ូហើយឥឡូវនៅស្រុក មកពីភូមិខ្ញុំច្រើនណាស់នៅសល់តែខ្ញុំ ពីរនាក់ហ្នឹងទេ មួយទៅស្រុកទៅខ្ញុំក៏នៅហ្នឹង ។

វណ្ណៈ ចឹងកាលចេញមកមានគ្នាច្រើនដែរ?

ស៊ាន់ៈ កាលចេញមកមានគ្នា២០០ទៅ៣០០នាក់នោះ ច្រើនណាស់ តែខ្ញុំមកក្រោយគេប្អូនខ្ញុំមកមុនទៀតតែវាទៅវិញដែរ ។

វណ្ណៈ ចឹងគាត់មានសំណាងដែលអត់អីអត់ស្លាប់?

ស៊ាន់ៈ បាទ!គិតទៅមកទាហានហ្នឹងតែពីនាក់ទេ ខ្ញុំនិងប្អូនខ្ញុំ មិនមែនអាប្អូនទី៣ទេ ។

វណ្ណៈ ចឹងកាលដែលអ៊ីមកចូលជាចលនាបដិវត្តហ្នឹង កាលហ្នឹងអ៊ីមានកូនហើយនៅ?

ស៊ាន់ៈ មានកូនហើយ មានកូនបីហើយ ។

វណ្ណៈ ចឹងអឺដាច់ចិត្តចុះមក?

ស៊ាន់ៈ បាទ!កាលហ្នឹងបើនៅក៏ងាប់ដដែរ ចឹងទាល់តែមក កាលហ្នឹងគិតថា ធ្វើទាហានដឹងថាជា ចំណី កាណុងទៅហើយ តែបើយើងមិនមកគេចោទយើងចេះចុះហើយយកយើងទៅវាយ ចោលទៅ វាខាតហើយវេទនាទៀត បើមកទាហានវាមានស្លាប់វាមានរស់ បើយើងកាន់ត្រង់ទៅវារស់ ហើយខ្ញុំធ្វើទាហានខ្ញុំត្រង់ណាស់ កូនប្រពន្ធគេ ទ្រព្យសម្បត្តិគេគឺអត់ មនុស្សក៏អត់សម្លាប់ទៀត មិនស្លាប់ទេ តែបើបាញ់គ្នាទៅវិញទៅមកខ្ញុំមិនដឹងទេ ត្រូវពីណាក៏ខ្ញុំមិនដឹង ព្រោះការពាររាង ខ្លួនណា តែបើថាចាប់បានហើយខ្ញុំមិនដែលសម្លាប់ពី ណាមួយអត់សោះតែម្តងមួយជីវិតខ្ញុំ ។

វណ្ណៈ ចឹងកាលហ្នឹងខាងកំពង់ស្ពឺហ្នឹង កាលហ្នឹងគេមានបែកកម្លាំងមុខព្រួញទៅខាងណាខ្លះទេ ដូច ជាកម្លាំងវាយសំដៅទីក្រុងភ្នំពេញអីចឹង វាយឲ្យឈ្នះទាហាន លន់ នល់ វិញដើម្បីទាមទារ សម្តេចមកវិញ ចឹងមានការរៀបចំកម្លាំងមុខព្រួញមុខសញ្ញាអីចឹងអ៊ំនៅមុខព្រួញខាង ណាដែល ពេលហ្នឹង?

ស៊ាន់ៈ ចេះក្លាយកាលហ្នឹងវារតាក់រតប់ច្រើនណាស់ វាពិបាកនិយាយណាស់ ខ្ញុំមកមិនទាន់ធ្វើជា ទាហានភ្លាមទេ គេមិនទុកចិត្តឲ្យយើងធ្វើទាហានទេ គេឲ្យទទួលខាងសេដ្ឋកិច្ចដឹកជញ្ជូន បាយមក ខាងសមរភូមិដឹកជញ្ជូនបាយចឹងទៅដើររកម្ហូបតាមភូមិតាមឃុំចឹងទៅ ដើម្បីផ្គត់ផ្គង់កងទ័ពរក ទិញគោទិញមាន់អីចឹងទៅណាសម្រាប់កងទ័ពហើយពេលចូលសមរភូមិ គេប្រើបាយស្មុគមិនចឹង ស្ពាយបាយស្មុគទៅសមរភូមិដើម្បីយកឲ្យកងទ័ពដល់ឆ្នាំ៧២ ហ្នឹងខ្ញុំបានធ្វើទាហានហើយ ពេញ សិទ្ធិវាយតែម្តង កាលហ្នឹងនៅក្នុងកងពលលេខ២ហ្នឹង មិនដឹងថាពីណាមេពីណាកូនអីទេ មេ ផ្ទាល់ប្រធានវរៈឈ្មោះ ឡាំ ខ្ញុំមិនបានចាំត្រកូលគាត់ទេ យូរហើយរហូតដល់នៅកង អនុសេនាធំហ្នឹងត្រូវជាឪពុករបស់កូនប្រសារខ្ញុំរាល់ថ្ងៃហ្នឹង តែគាត់ស្លាប់ហើយឈ្មោះ គីម ឈ្មោះ ង៉ែត គីម គាត់នៅស្រុកត្រាំកក់ នៅជិតថ្នល់បែកគូសនោះ តែឥឡូវគាត់ស្លាប់ ហើយ ។

វណ្ណៈ ចឹងគាត់ប្រធានវរសេនាធំ?

ស៊ាន់ៈ គាត់ប្រធានវរសេនាតូចទេ មិនមែនទេ ឈ្មោះ ឡាំ ហ្នឹងគាត់ជាប្រធានវរៈហើយតា គីម ហ្នឹងគាត់ប្រធានកងធំ ហើយខ្ញុំនៅជាមួយគាត់រហូតមកដល់គ្នាហ្នឹងវាយរំដោះភ្នំពេញ នៅរហូត ជាគាត់ហ្នឹងទៅ ។

វណ្ណៈ អ៊ំនៅជាមួយឈ្មោះ ឡាំ ហ្នឹងគាត់ជាប្រធានវរសេនាធំឬវរសេនាតូច?

ស៊ាន់ៈ ប្រធានវរសេនាតូច ។

វណ្ណៈ វរសេនាតូចលេខប៉ុន្មានទៅ?

ស៊ាន់៖ ដូចជា៣៥អីចឹងកាលនោះ៣៥ ខ្ញុំមិនបានចាំអស់ទេ វាយូរពេកហើយ ។

វណ្ណៈ ចឹងកាលនៅខាងកំពង់ស្ពឺហ្នឹងគេហៅតំបន់ប៉ុន្មានដែរ?

ស៊ាន់៖ ខ្ញុំមិនបានដឹងទេ តែចេះកាលដែលយើងធ្វើទាហានហ្នឹងនៅក្នុងកងពល២ហ្នឹងនៅក្នុងតំបន់ និរតី ភ្នំពេញ ចូលដំបូងណា ខ្ញុំមកវាយនៅម្តុំក្រូចសើចក្រូចអី វត្តស្លែងអីយើងរាល់ថ្ងៃហ្នឹង កាលហ្នឹងមិនមានដូចឥឡូវទេ កាលហ្នឹងមានសុទ្ធតែដើមសង្កែតាមភ្លឺស្រែដំនាន់អា បេ៥២នោះ ។

វណ្ណៈ ចឹងកាលហ្នឹងមានទម្លាក់គ្រាប់ខ្លាំង?

ស៊ាន់៖ អូស!ខ្លាំងណាស់ ។

វណ្ណៈ កងពលទី២អ៊ឹ?

ស៊ាន់៖ កាលនោះនៅកងពល២ ខ្ញុំនៅមិនបានយូរទេ ហើយវាយម្តុំវត្តស្លែងហើយគេបញ្ជូនមក កំពង់ត្រាំមកវាយកំពង់ត្រាំហ្នឹងមិនបានវាយទេ ស្នាក់នៅភូមិដើមប៉ែនហ្នឹងក៏ឆ្លងមក តាមផ្លូវអន្តតាឡឹក ថ្នល់ទទឹងយើងនេះ មកខាងខដុត្ត មកខាងខដុត្តហ្នឹងគេផ្តាច់មួយវរៈ ហ្នឹងមកចូលកងពលទី១វិញ បស្ចឹមភ្នំពេញ ។

ដានី៖ ចឹងអ៊ឹផ្តាច់ចូលមកកងពលទី១វិញ?

ស៊ាន់៖ បាទ!កងពលទី១វិញហើយ ទី១ហ្នឹងមាន តា សឿង តែខ្ញុំមិនដែលស្គាល់មុខទេ ហើយមានតា សេង ហៅ ឆន ហ្នឹងគាត់ប្រធានវរសេនាធំនៅខាងបស្ចឹម នៅខាងតាំងពោធិ៍ ។

ដានី៖ តា ឆន ហ្នឹងក្រោយមកគាត់នៅ៨០២?

ស៊ាន់៖ មិនមែនទេ មិនមែនតា ឆន ហ្នឹងទេ តា ឆន ហ្នឹងកូនប្រសារ សុន សេន នោះ សេង ហៅ ឆន ក្រោយនេះឥឡូវនេះគាត់នៅខាងវាលវែង ។

ដានី៖ គាត់ជាមេឃុំអន្លង់វាម?

ស៊ាន់៖ ទេ មិនស្គាល់ មិនដឹងថាគេធ្វើអីទេ ឥឡូវនេះ បែកគ្នាយូរហើយ ចឹងគាត់ជាមេឃុំអន្លង់រាប ។

វណ្ណៈ ចឹងកាលអ៊ឹដូមកកងពលទី១វិញហ្នឹងប្រហែលជាឆ្នាំណាដែរ?

ស៊ាន់៖ ឆ្នាំ៧២ដែរ មិនទាន់ចូល៧៣ទេ ។

ដានី៖ ជាមួយ តា ម៉េត ដែរ?

ស៊ាន់៖ តា ម៉េត ហ្នឹង ដូចជាអនុកងពលកាលហ្នឹង ។

វណ្ណៈ តា ម៉េត តា រវៃ?

ស៊ាន់៖ មិនដែលស្គាល់មុខទេ តែខ្ញុំស្គាល់តា រវៃ ច្បាស់ តា រវៃ គាត់ស្រឡាញ់ខ្ញុំណាស់ មនុស្សដូចថាប្រើទៅណាចេះតែទៅចឹងទៅណាស់ កាលនោះគេនិយាយថានិន្នាការមិនល្អ និន្នាការត្រូវបង

ប្អូនញាតិមិត្តមាមីងអ៊ីបដិវត្តគេកំទេចហើយគេដាក់ម្ដុំ កាលនោះសម័យខ្ញុំ ខ្ញុំនិយាយត្រង់ ខ្ញុំមិនលាក់ទេ គេដាក់ម្ដុំតែបានកូនប្រសារខ្ញុំរាល់ថ្ងៃហ្នឹងគាត់ ស្រឡាញ់ខ្ញុំ ខ្ញុំធ្វើអីខ្ញុំមិនខ្លាចងាប់ទេ ខ្ញុំថាខ្ញុំមកសម្រាប់ងាប់ទេ បើទៅផ្ទះវិញក៏ងាប់នៅ ក៏ងាប់ចេះតែទៅៗ ចឹងណាស់គាត់ស្រឡាញ់ខ្ញុំគេដាក់ចឹងទៅគាត់យកនៅជាមួយគាត់ ហ្នឹងធ្វើខាងសេដ្ឋកិច្ចខ្លះទៅ គេងាប់ច្រើនពេកក៏ចូលទៅវាយនិងគេទៅវាយយូរៗទៅចូល ជាយុវជនបានឡើងធ្វើជាមេក្រុម បានធ្វើមេក្រុមហើយគេទទួលស្គាល់ចឹងទៅគេនៅតែ ពិនិត្យថាយើងសមាសភាពមិនល្អ ចង់និយាយចេះ ។

ដានី: ខាងនីរតីមានកងពលទី១ទី២និងទី៣?

ស៊ាន់: បាទ!មានបីកងពល ។

ដានី: កងពលទី១ របស់ តា ឈឿង?

ស៊ាន់: តា សឿង ។

ដានី: ចឹងទី២?

ស៊ាន់: ទី២ តា ប៊ិត កាលនោះ សំ ប៊ិត ហ្នឹង កងពលទី២ កាលនោះ ហើយកងទី៣ហ្នឹងដូច ជាមិនមានទី៣ទេ មាន១៦៤ ខាងសមុទ្រ ។

ដានី: កងពល តា មាស មុត ហ្នឹង?

ស៊ាន់: ហ្នឹងហើយ តា មុត ក្រោយមកខ្ញុំក៏ចូលទៅក្នុងកងពលហ្នឹងជាបន្តបន្ទាប់មករហូតដល់ យើងរំដោះភ្នំពេញហ្នឹង ខ្ញុំរបួស ខ្ញុំទៅដេកពេទ្យនៅចម្ការក្រូចអមលាំងហ្នឹង គេវាយរំដោះភ្នំពេញ ។

វណ្ណៈ: ចឹងវាយរំដោះភ្នំពេញ ចឹងអ៊ំអត់បានចូលទេ?

ស៊ាន់: ខ្ញុំមិនបានចូលទេ គេទៅដល់ភ្នំពេញបានមួយថ្ងៃបានខ្ញុំមក មកហើយខ្ញុំទៅឈរជើងនៅ បន្ទាយហែម អេង នោះ ផ្លូវយើងចោមចៅ ។

ដានី: ហែម អេង ហ្នឹងជាឈ្មោះ នាយទាហាន លន់ នល់?

ស៊ាន់: លន់ នល់ ព្រោះ ង៉ែត គីម គាត់ឡើងជាប្រធានវរៈហើយ ខ្ញុំនៅមន្ទីរជាមួយគាត់ ខ្ញុំធ្វើប្រធានមន្ទីរមុនដំបូងមានតែម្នាក់ទេ ធ្វើប្រធានមន្ទីរហ្នឹង តិចចាប់ពួកគាត់ គាត់ចេះតែតម្លើងៗទៅឲ្យគាត់ទៅតាមកងចឹងទៅណាស់ យកខ្ញុំធ្វើប្រធានមន្ទីរ ។

ដានី: ប្រធានវរសេនាធំ?

ស៊ាន់: វរសេនាតូចមិនមែនវរសេនាធំទេ អត់បានឡើងវរសេនាធំទេ កាលហ្នឹងនោះ ខ្ញុំនៅប្រធានមន្ទីរ ។

វណ្ណៈ: ចឹងកាលហ្នឹងអ៊ំត្រូវរបួសចឹងមួយថ្ងៃបានអ៊ំឡើងទៅ?

ស៊ាន់: បាទ!មួយថ្ងៃ បានគេបញ្ជូនមកតាមកងចឹងណាស់ បញ្ជូនមកតាមកងទាំងអស់ ។

វណ្ណៈ ចឹងពេលមកដល់ទីក្រុងភ្នំពេញហ្នឹង អ៊ំឃើញសភាពការណ៍យ៉ាងម៉េចដែរ?

ស៊ាន់ៈ ទេ ខ្ញុំមិនបានចូលក្រុងទេ ខ្ញុំនៅបន្ទាយ ហែម អេង ដូចខ្ញុំបានជំរាបចឹង ។

វណ្ណៈ ចឹងអ៊ំនៅត្រឹមបន្ទាយទេ?

ស៊ាន់ៈ បាទ!មកដល់ចុះធម្មតាប្រធានមន្ទីរគេមានឲ្យដើរណា គេឲ្យនៅគ្រប់គ្រងកន្លែងមន្ទីរសំភារៈ បន្តិចបន្តួចចឹងទៅគ្រប់គ្រងចឹងទៅ ប៉ុន្តែខ្ញុំចង់ដឹងភ្នំពេញដែលហ្នឹង កាលហ្នឹងមាន ម៉ូតូអីច្រើន បេះតែជិះទៅជិះចូលភ្នំពេញទៅ ខ្ញុំឃើញគេជម្លៀសប្រជាជនមកតាមជនបទចឹងទៅដើរចឹងទៅ ធម្មតាជម្លៀសមានបានឥវ៉ាន់ច្រើនទេ ។

ដានីៈ យ៉ាងម៉េចទៀតទៅពេលអ៊ំនៅមន្ទីរហ្នឹង នៅក្នុងមន្ទីរហ្នឹងនៅក្នុងកងពលណាទៅ?

ស៊ាន់ៈ កាលហ្នឹងនៅក្នុងកងពល៥០២ ក្រោយមក៥០២ហ្នឹងគេមិនដាក់ទៅខាងអាសកាសចរណ៍ ដល់ក្រោយមកទៀតគេចាត់ខ្ញុំឲ្យឡើងកងធំហើយកាលហ្នឹង ចេញពីប្រធានមន្ទីរឡើងកងធំ ឡើងកងធំហ្នឹងយាមនៅពោធិចិនតុងហ្នឹង យាមនៅប៉ែកខាងត្បូង យាមកន្លែងអាកាសចរណ៍ ធម្មតាអ្នកយាមមានបានដើរទៅណា ។

វណ្ណៈ ប្រធានកងធំប្រធានវរសេនាធំឬប្រធានកងធំ?

ស៊ាន់ៈ ប្រធានកងធំ ប្រធានវរសេនាធំហ្នឹង សេង ហៅ ឆន ហ្នឹងដូចខ្ញុំប្រាប់ហ្នឹង ហើយពួកខ្ញុំសុទ្ធពួកនិន្នាការហ្នឹងកាលហ្នឹង ជាសមាសភាពណាស់ គេឲ្យធ្វើស្រែនៅអូរបែកក្អមហ្នឹង ។

វណ្ណៈ កាលហ្នឹងនៅភ្នំពេញធ្វើស្រែ?

ស៊ាន់ៈ បាទ!ធ្វើស្រែអូរបែកក្អមហ្នឹងណាស់ មេខ្ញុំ ង៉ែត គីម ហ្នឹង តាំងខ្ញុំអីហ្នឹងធ្វើហ្នឹងដល់ ក្រោយមកមិនដឹងជាយ៉ាងម៉េចទេ គេដកខ្ញុំឲ្យទៅខាងរថភ្លើង ។

ដានីៈ ឆ្នាំណាដែលគេដកអ៊ំ?

ស៊ាន់ៈ ដកទៅនៅកន្លែងរថភ្លើងហ្នឹងឆ្នាំ៧៨ ។

វណ្ណៈ កាលមុនដកអ៊ំជាប្រធានកងធំ?

ស៊ាន់ៈ បាទ!ប្រធានកងធំនៅយាមកន្លែងអាកាសចរណ៍ហ្នឹង ។

ដានីៈ អ៊ំខ្ញុំចង់ដឹងបន្តិចកន្លែង៥០២ហ្នឹងមានប៉ុន្មានវរនោធំទៅ?

ស៊ាន់ៈ មានបី មាន៥១-៥២ មិនដឹងជាប៉ុន្មានទៀតទេ ដូចជា៥៣អីប៉ុន្មានទេ ៥៣ចឹងមិនដឹង ខ្ញុំមិនចាំទេ តែខ្ញុំនៅ៥១ ប្រធានគ្រប់គ្រង៥១ហ្នឹងឈ្មោះ អ៊ី វ៉ិន ទេ ស្រុកគាត់នៅ ខាងស្រុកស្អាង ភាគច្រើនអ្នកនៅខាងភូមិភាគបូព៌ា ប្រធាន ៥២ ហ្នឹង តា សេង ដែលខ្ញុំថាហ្នឹង ។

ដានីៈ ៥២ សេង ហៅ ឆន?

ស៊ាន់៖ បាទ!សេង ហៅ ឆន ហើយមួយទៀតណាទេខ្ញុំមិនចាំទេ មិនមែនប្រឡំទេ នៅក្នុងអាកាសចរណ៍ មួយទៀតគេហៅថាខាងជាងអាកាសចរណ៍ហ្នឹង វាមានវរសេនាធំ ។

ដានី៖ វរសេនាធំ សេង ហៅ ឆន ហ្នឹងខាងអាកាសចរណ៍?

ស៊ាន់៖ អាកាសចរណ៍ ប៉ុន្តែ តា ឆន ហ្នឹង អត់ទេ អះ! តា វ៉ន ហ្នឹងគាត់អត់ទេ ទីតាំងគាត់នៅទួលកី ហើយវរៈៗគាត់ហ្នឹងរៀបចំខាងៗទាំងអស់ យាមអាកាសចរណ៍ពីខាងត្បូង ហើយមានមួយទៀតនៅបឹងទំពុន ។

ដានី៖ បឹងទំពុន ហ្នឹងវរៈលេខប៉ុន្មាន?

ស៊ាន់៖ បឹងទំពុនហ្នឹងវរៈលេខប៉ុន្មានទេ ខ្ញុំមិនសូវចាំដែរ ប៉ុន្តែពួកហ្នឹងគេស្លាប់អស់ហើយ គេកំទេចអស់ហើយ ។

ដានី៖ អាហ្នឹងខាងបូព៌ា?

ស៊ាន់៖ បាទ!បូព៌ាបាត់ខ្លួនអស់ហើយដោយទាំងពួកខ្ញុំពួកអីវ៉ា ។

ដានី៖ តែខាង៥២របស់តា សេង ហៅ ឆន ហ្នឹងនៅកាពារព្រលាន?

ស៊ាន់៖ បាទ!ការពារព្រលាន ព្រលានហ្នឹងមានមួយវរៈទៀតវរៈធំគេទៀតដែលខ្ញុំមិនបានចាំលេខ ។

វណ្ណៈ៖ វរសេនាធំដែរ?

ស៊ាន់៖ បាទ!អាហ្នឹងនៅខាងទាំងប្រេងទាំងជាងយន្តហោះអី ។

ដានី៖ បឹងមិនមែនបីវរសេនាធំទេ?

ស៊ាន់៖ បី តែអាពីរនោះរបៀបគេឯករាជ្យអីចឹងណាស់ មាន តា បៃ មាន ខ្លឹង ។

ដានី៖ តា បៃ នៅភ្នំព្រឹកហ្នឹង?

ស៊ាន់៖ មិនដឹងជានៅណាទេខ្ញុំ ខ្ញុំមិនស្គាល់ផងកាលហ្នឹង គាត់ស្លាប់ឬក៏រស់ទេ ហើយ តា ណាំ តា ណាំហ្នឹងក៏នៅក្នុងហ្នឹងដែរ តែគាត់មកឈរជើងនៅបាត់ដំបងខាងយន្តហោះដែរ ខ្ញុំចាំមិនអស់ទេ ទាល់តែរកពួកខ្ញុំស្រាវជ្រាវ ចង់មានប្រសាសន៍អីទៀត ។

ដានី៖ ដល់ឆ្នាំ៧៨ ពេលហ្នឹងអីផ្លាស់មក?

ស៊ាន់៖ ៧៨បេះ មុនរដ្ឋប្រហារ ប៉ុល ពត ដែលយួនចូលស្រុកយើងហ្នឹងណាស់ ខ្ញុំគេឲ្យខ្ញុំទៅគ្រប់គ្រងនៅព្រលានកំពង់ឆ្នាំង ។

វណ្ណៈ៖ បឹងអីទៅកំពង់ឆ្នាំងទៀត?

ស៊ាន់៖ ទៅធ្វើផ្លូវធ្វើអី ទៅក្រាំងស្ដៀលខ្ញុំហ្នឹងហើយអ្នកធ្វើនោះ ។

វណ្ណៈ៖ បឹងកាលនៅរថភ្លើងនៅក្នុងឆ្នាំ៧៨ហ្នឹងដែរ?

សាន់៖ ៧/៨ដែរ ហើយក្នុង៧/៨ហ្នឹង ទៅកំពង់ឆ្នាំង ទៅកំពង់ឆ្នាំងបានតែបីខែដកមកខាងរថភ្លើងវិញដដែល ។

វណ្ណៈ ចឹងអឺគ្រប់គ្រងព្រលានកំពង់ឆ្នាំង?

សាន់៖ អត់ទេ គ្រប់គ្រងមួយកងទេ គេហៅថា កងមាននិន្នាការនយោបាយ ហើយខ្ញុំមនុស្សល្អត្រឹមត្រូវហ្នឹងគេឲ្យគ្រប់គ្រងអ្នកខូចខិលដូចថាអ្នកជាប់និន្នាការមិនល្អហ្នឹងគេយកទៅឲ្យខ្ញុំ ។

ដានី៖ ចឹងពីណាគ្រប់គ្រងធំនៅហ្នឹង?

សាន់៖ គ្រប់គ្រងធំ កាលនោះមាន ឈ្មោះ តា រ៉ៃ មាន តា ធូក មិនដឹងជាទៅណាអស់ទេ លែងដឹងអស់ហើយឥឡូវ ។

វណ្ណៈ មួយកងហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

សាន់៖ មួយកងហ្នឹងគេឲ្យខ្ញុំមើលហ្នឹងប្រហែលជាមួយវរៈ តែខ្ញុំក៏មិនទាន់ទទួលវរៈទេ តែកម្លាំង វាមានបីអនុសេនាធំហើយ ទទួលជាបណ្តោះអាសន្ន ។

វណ្ណៈ មានប៉ុន្មានរយនាក់ទៅ?

សាន់៖ ប្រហែលជា៥០០នាក់ទៅ ខុទាហណ៍មួយកងធំវាមាន១០០ជាង ហើយមានបីកងធំ វាខ្ទង់៧០០អីហ្នឹង ធ្វើព្រលាន តែកងខ្ញុំធ្វើផ្លូវទៅក្រាំងស្តៀល ។

វណ្ណៈ ចេញពីព្រលានទៅក្រាំងស្តៀល?

សាន់៖ បាទ!ចេញពីព្រលានទៅក្រាំងស្តៀល ។

ដានី៖ អឺមានចាំថា ព្រលានគេធ្វើយ៉ាងម៉េចទេ អីយ៉ាងម៉េចទេ មានមនុស្សប៉ុន្មានដែលទៅធ្វើហ្នឹងអឺអាចដឹងទេ?

សាន់៖ ខ្ញុំចាំមិនបានទេ ហើយខ្ញុំនិយាយទៅមានពេលស្មាហ្នឹង មនុស្សច្រើនណាស់ធ្វើព្រលាន ។

វណ្ណៈ មានដល់រាប់ពាន់នាក់ទេ?

សាន់៖ ចង់ម៉ឺននោះ មិនមែនពាន់ទេ វាមានច្រើនសំណាន់ ធ្វើរូងភ្នំធ្វើអី ហើយខ្ញុំទទួលមួយផ្លូវ ទៅក្រាំងស្តៀលទេ ខ្ញុំគេឲ្យទទួលផ្លូវហ្នឹងធ្វើជាមួយចិន ចិនហ្នឹងស្រឡាញ់ខ្ញុំណាស់កាល នោះព្រោះខ្ញុំធ្វើល្អ ចង់និយាយថាធ្វើល្អ ឲ្យតែល្ងាចហៅខ្ញុំទៅស្រាបៀរចិនហើយ ។

វណ្ណៈ ចឹងមានអ្នកបកប្រែទេ?

សាន់៖ បាទ!មាន ដល់បានបីខែគេដកខ្ញុំមកវិញដដែល ។

វណ្ណៈ ចឹងបានបីខែមកខាងរថភ្លើងវិញ?

សាន់៖ មករថភ្លើងវិញ មករថភ្លើងហ្នឹងត្រូវគេរដ្ឋប្រហារហ្នឹង កូនប្រពន្ធអីគេបញ្ជូនអស់ល់រលីងហើយគេរត់អស់ហើយ ខ្ញុំនៅកន្លែងរថភ្លើងតើ ឃើញវៀតណាមចូលពេញហើយខ្ញុំមិន

ទាន់ចេញទេ នៅតើចុះបើគេរត់ចោលខ្ញុំម៉េចដឹង ខ្ញុំនៅកន្លែងស្ថានីយយើងហ្នឹង ស្ថានីយ៍រាល់ថ្ងៃហ្នឹង ។

ដានី: ចឹងពេលហ្នឹងមកគ្រប់គ្រងនៅរថភ្លើងវិញ?

ស៊ាន់: ខ្ញុំគ្រប់គ្រងជាមួយ តា វ៉ៃ ប៉ុន្តែខ្ញុំទៅដឹកជញ្ជូន ដឹកអាវុធដឹកគ្រាប់រំសេវអីពីកំពង់សោម ហ្នឹងមិនដឹកតាមរថភ្លើង ដល់ដឹកមកដល់កន្លែងហ្នឹងវា ដូចថាថ្ងៃរដ្ឋប្រហារណាស់ ថ្ងៃ៧មករា ហ្នឹង គេទៅអស់បាត់ ទៅដល់ឃើញរថក្រោះពាសវាលពាសការហ្នឹង គេសួរ ថាម៉េចមិនទៅ ខ្ញុំថាដឹកជាទៅណាអត់ដឹងផង ចឹងគេថានៅហ្នឹងហើយ ខ្ញុំថានៅយ៉ាងម៉េច ប្រពន្ធកូន ខ្ញុំគេយកចេញអស់ហើយ ដឹងទៅខាងណា ខ្ញុំនិយាយតាមត្រង់ ហី ចឹងវាមាន ខ្មែរទេ មិនមែនវៀតណាមទេ ខ្មែរហ្នឹងគេថា គេថាឥឡូវអូនឯងចេះទៅ គាត់ចាស់ ហើយអូនឯងចេះ ទៅចុះពីលើរថក្រោះមកថា អូនឯងទៅយកប្រពន្ធកូនមកវិញ មិនបាច់តាមពួក ប៉ុល ពត ទេ ចឹងពួក ប៉ុល ពត ទៅណាអស់ហើយ គេថា ពួក ប៉ុល ពត គេវាយរត់ចូលព្រៃអស់ហើយ ខ្ញុំឆ្លើយបាទ ខ្ញុំមានគ្នាបីនាក់នៅជាមួយខ្ញុំបើឡាន ៤០៤មកតែម្តងមកខាងកំពង់ឆ្នាំង ទេ មិនមែនកំពង់ឆ្នាំងទេ មកដល់រ៉ាក្រាំងស្តៀល ហ្នឹងក៏ជួបពួកទាហានថ្វាប់នៅជាមួយគ្នា វាថាកុំចាញ់យួន កុំចាញ់បោកយួន យួនចូល ពេញនគរអស់ហើយ គេថាកុំទៅទៀតទៅទៀត គេកាត់ក ខ្ញុំថាគេអត់មានកាត់កទេ គេឲ្យមកយកប្រពន្ធខ្ញុំទៅវិញ ឲ្យខ្ញុំនៅធ្វើការជាមួយគេវិញ ហើយទទួលប្រពន្ធខ្ញុំគាត់ជិះរថភ្លើងអាអូតូរ៉ៃទៅប៉ោយប៉ែតទៅអារ៉ាញ់ទៅជាមួយចិន ។

វណ្ណៈ: បាទ ។

ស៊ាន់: បែកបាក់គ្នាអស់ទៅ ។

វណ្ណៈ: ចឹងខ្ញុំចង់សួរបកក្រោយបន្តិចដែរ នៅពេលអ៊ំធ្វើចលនាឈ្នះហើយមកនៅភ្នំពេញមក នៅកំពង់ឆ្នាំងអីហ្នឹង កាលហ្នឹងអ៊ំបានទៅយកប្រពន្ធពីស្រុកកំណើតមកនៅជាមួយដែលចឹង?

ស៊ាន់: បាទ ។

វណ្ណៈ: ចឹងពេលអ៊ំទទួលជ័យជម្នះហើយអ៊ំបានជួបជុំប្រពន្ធកូនវិញ?

ស៊ាន់: បាទ ។

វណ្ណៈ: ចឹងខ្ញុំចង់សួរទាក់ទងហ្នឹងព្រលានខេត្តកំពង់ឆ្នាំងបន្តិចទៀត ចឹងខាងរបបប្រជាធិបតេយ្យ ហ្នឹងធ្វើព្រលានច្បាស់ជាមានគំរោងអីផ្សេងទៀតហើយមិនចឹង ចឹងកាលដែលធ្វើព្រលាន ហ្នឹងមានជំនួយពីចិនមកមានអាវុធដឹកមកមានសំភារៈជាគ្រឿងយន្តហោះមានដឹកមកដល់ប្រទេសកម្ពុជាយើងហ្នឹងហើយដែលអត់ឬមិនទាន់មានទេ កាលហ្នឹង?

សាន់៖ មិនទាន់មានទេ ក្អួយមិនទាន់ទាំងអស់ តែធ្វើហ្នឹងខ្ញុំមិនទាន់ដឹងច្បាស់អីដែលគ្រាន់ថាធ្វើ ព្រលាន ឲ្យល្អទៅចិនជួយយន្តហោះអីមក កាំភ្លើងធំអីដាក់ហ្នឹងដើម្បីវាយជាមួយយួនតែប៉ុណ្ណឹងទេ វាយ យួន ។

វណ្ណៈ តែសំភារៈមិនទាន់ដឹកញ្ជូនមកទេ?

សាន់៖ នៅទេ ។

វណ្ណៈ តែកាំភ្លើងអីពេលហ្នឹងមានមកនៅ?

សាន់៖ មានមកខ្លះហើយ ។

វណ្ណៈ មានកាំភ្លើងទំនើបៗដែលអី?

សាន់៖ កាំភ្លើងមិនសូវមានកាំភ្លើងធំទេ កាលជំនាន់ខ្ញុំនៅតាមរថភ្លើងដឹកហ្នឹងណាស់ មានតែយន្ត ហោះ ធុន៥ ធុន៦ទេ ដឹកមកតែមិនទាន់បានតម្លើងទេ គេយកមកតម្លើងភ្នំពេញទេ ។

វណ្ណៈ ប្រហែលជាប៉ុន្មានគ្រឿងដែរ?

សាន់៖ ចាំមិនច្បាស់ ។

វណ្ណៈ ចឹងមានន័យថា គ្រឿងយន្តហោះហ្នឹងគេដឹកយកមកបណ្ដើរៗហើយ?

សាន់៖ ដឹកយកមកនៅលើរថភ្លើងមិនទាន់បាននេះណា ក៏យួនចូលពេញ ។

វណ្ណៈ សុទ្ធតែលុយៗថ្លៃៗណាស់?

សាន់៖ ក្អួយអើយនិយាយទៅបើទៅក្រអូបដូចផ្លែមានចឹង ខ្ញុំនិយាយដោយត្រង់តែម្ដងខ្ញុំមិនលាក់ទេ ។

វណ្ណៈ ចឹងកាលធ្វើព្រលានហ្នឹងឲ្យតែខាងអាកាសចរណ៍ក្រែងឈ្មោះ ស៊ូ មេ៉ត គាត់ជាអ្នកគ្រប់គ្រង ទាំងអស់ កងពល៥០២ហ្នឹងឈ្មោះ ស៊ូ មេ៉ត គ្រប់គ្រងទាំងអស់?

សាន់៖ បាទ ។

វណ្ណៈ ទាំងព្រលាននៅភ្នំពេញទាំងព្រលានខេត្តកំពង់ឆ្នាំង?

សាន់៖ ទាំងអស់ ព្រលានខេត្តបាត់ដំបងអីហ្នឹងគាត់គ្រប់គ្រងរួមតែម្ដង ។

វណ្ណៈ ចឹងតា វ៉ៃ កាលនោះគាត់?

សាន់៖ តា វ៉ៃ កាលនោះថា អនុក៏បាន តា វ៉ៃ គេចេះតែចាត់តាំងដូចខ្ញុំចឹង ម្ដងទៅខាងរថភ្លើង ចឹងទៅម្ដងទៅកន្លែងយន្តហោះចឹងទៅ តា វ៉ៃ គាត់មិនសូវជាអ្នកចេះច្រើនអីទេ គាត់ពីណា ក៏ ប្រើដែរ ។

វណ្ណៈ ចឹងបើតាមអ៊ីសង្កេតមើលនៅក្នុងរន្ទង់ដែលអ៊ីបានមកព្រលានកំពង់ឆ្នាំងហ្នឹង ដោយសារថា នៅ ក្នុងសម័យខ្មែរក្រហមហ្នឹង តាំងមើលឯកសារទៅដឹងថា សូម្បីតែយើងធ្វើធំនៅក្នុងសម័យ ខ្មែរក្រហមក៏ពិបាកនិង្សរួចខ្លួនដោយសារគណៈតំបន់គណៈអីប្រធានកងពលផ្សេងត្រូវបានថ្នាក់លើ

បេះបោទថា បានចូលជាសេអ៊ីអាអីចឹង ហើយឈានទៅចាប់ប្រធានកងពល ប្រធានគណៈតំបន់អី បេះតែមានចាប់បន្តបន្ទាប់ចឹង ហើយនៅកំពង់ឆ្នាំងហ្នឹង តើមានព្រឹត្តិការណ៍ចាប់នាយទាហានផ្សេងៗដែលអីពេលហ្នឹង តាមអ៊ីដឹង?

ស៊ាន់: អត់ដឹងទេ រឿងគេចាប់អីគេមិនអាចឲ្យយើងដឹងទេ គេមិនអាចប្រាប់យើងទេ គេមិន អាចប្រាប់យើងទេ ព្រោះយើងគេឲ្យគ្រប់គ្រងកម្លាំងមួយ ក្នុងមួយអាទិត្យគេប្រជុំម្តងគេ សួរថាឈ្មោះ អ្នកនេះៗចឹងមេៗណា ចាប់ពីអនុវរសេនាធំគេសួរថា អានេះបេះចុះ អ៊ីខ្ញុំថាអត់ទេ ឃើញតែគ្នាធ្វើការល្អ ហើយគ្នាប្រឹងណាស់កាលនោះ ខ្លាចងាប់មនុស្ស យើងមិនមែន មិនដឹងទេ ថាកន្លែងគេដកទៅសុទ្ធតែជាប់និន្នាការនយោបាយហើយថ្ងៃណា គេយកទៅសម្លាប់ហើយ តែគេមិនបានប្រាប់យើងទេ សូម្បីតែដកមនុស្សចេញពីកន្លែង ខ្ញុំក៏មានដក ប៉ុន្តែមិនបានប្រាប់ខ្ញុំទេ គ្រាន់គេខ្ចីកម្លាំងទៅធ្វើអានេះទៅធ្វើអានោះចឹង គេខ្ចីរបៀបខ្ចី ខ្ចីហើយមិនដែលឃើញសងទេ។

វណ្ណៈ: ចឹងមានន័យថា គេខ្ចីហើយបាត់ខ្លួនតែម្តងទៅ?

ស៊ាន់: បាទ។

វណ្ណៈ: ចឹងពេលធ្វើការធ្ងន់អីចឹងមានចំណីអាហារគ្រប់គ្រាន់ទេ?

ស៊ាន់: មានគ្រប់គ្រាន់។

វណ្ណៈ: ចឹងមានខាងចិនអីមានទំនាក់ទងលេងសើចជាមួយយើងទេ?

ស៊ាន់: ធម្មតា។

វណ្ណៈ: ឬមួយគេលេងសើចជាមួយមេៗទេ?

ស៊ាន់: កូនចៅក៏ធម្មតាដែរ ធម្មតាគេបរទេសហើយជាមួយយើងគេមានសាមគ្គីល្អណាស់ មិនថាអ្នកណាយ៉ាងម៉េចទេ គេមិនដឹងទេ ដឹងថាល្អ តែពេលគេហៅទៅជប់លៀងគេហៅតែមេទេ អ្នកណាគ្រប់គ្រងផ្នែកណាចឹងទៅប្រធានអនុប្រធានហៅទៅចឹងណាស់ ហៅទៅ មើលកុនអីចឹងទៅជប់ហើយមើលកុនចឹងទៅ។

វណ្ណៈ: តាមអ៊ីបានដឹងថា មានជំនាញការចិនមានច្រើនទេ?

ស៊ាន់: យើ!មានមួយកងពល កងពលខ្ញុំនៅចាំទេ តា ជុងសឺ ហ្នឹងប្រធានកងពលខាងបច្ចេកទេសឈ្មោះ ជុងសឺ។

ដានី: អ៊ីនិយាយជាមួយគាត់ជាភាសាខ្មែរឬភាសាចិន?

ស៊ាន់: ខ្ញុំអត់បេះជងនិយាយខ្មែរមានអ្នកបកប្រែ អ្នកបកប្រែហ្នឹងចិនស្រីៗទេ ចិនដែលចិននៅស្រុកយើង តែឥឡូវមិនឃើញចិនទាំងអស់ហ្នឹង។

វណ្ណៈ ចឹងមានចិនមួយកងពលច្រើន?

ស៊ាន់ៈ បាទ!ចុះគេចែកគ្រប់សំណង់នោះមនុស្សច្រើនណាស់ តាំងពីភ្នំពេញមករហូតដល់កំពង់ឆ្នាំង សម្រុកធ្វើអត់មានឈប់ទេ គ្រឿងចក្ររបស់ចិនទាំងអស់ ។

វណ្ណៈ ខ្ញុំបានជួបបង១ខ្លះគាត់ថា មានដកកម្លាំងពីខេត្តកំពង់ឆ្នាំងទៅដល់ដែនវៀតណាមដើម្បី វាយជាមួយវៀតណាមដែរ?

ស៊ាន់ៈ ខ្ញុំមិនបានដឹងទេ តែដូចខ្ញុំថាចឹងគេឲ្យយើងរគប់គ្រងមួយកងហ្នឹងមាន៦០០ទៅ៧០០ចឹង បន្តិចគេដក៥០បន្តិចគេដក៦០ មិនដឹងជាគេយកទៅខាងណាទេ គេមិនបានរ៉ាវប់យើងទេ គេមានដកចឹងមែន ។

វណ្ណៈ ចឹងពីឆ្នាំ១៩៧៥ដល់៧៩អ៊ឹមានបានទទួលតំណែងអីដែរ?

ស៊ាន់ៈ ពី១៩៧៥ដល់៧៩បានទទួលតំណែងអនុសេនាធំ អនុសេនាធំហើយបានមកគ្រប់គ្រងហ្នឹង ។

វណ្ណៈ នៅឆ្នាំ១៩៧៩ ពេលវៀតណាមចូលមកដល់ព្រឹបហ្នឹង ពេលហ្នឹងអ៊ឹចង់សម្រេចចិត្តទៅ ស្រុកកំណើតវិញឬចង់ទៅជាយដែន?

ស៊ាន់ៈ អត់ទេ ដូចខ្ញុំបានជំរាបខាងដើមរួចហើយ ពេល៧៩ហ្នឹង ខ្ញុំនៅក្នុងភ្នំពេញហ្នឹងគេចូល ពេញអស់ហើយពេលវៀតណាមចូលនោះ ហើយខ្ញុំគេសួរថា ម៉េចបានជាមិនរត់ហ្នឹងគេ ខ្ញុំថាអត់ដឹងគេទៅណា ដល់ចឹងគេថា ប៉ុល ពត ចាញ់រត់អស់ហើយ នេះទ័ពរណសិរ្សសង្គ្រោះជាតិមកដើម្បីរំដោះបងប្អូនចឹងមិនបាច់ទៅទេ ខ្ញុំថាប្រពន្ធកូនខ្ញុំគេយកទៅណាទៅ ណីអស់ហើយឲ្យខ្ញុំនៅយ៉ាងម៉េចកើត គេថាចឹងទៅយកវិញទៅ ទៅយកហើយមកវិញ ខ្ញុំជំរាបម្តងហើយរួចហើយមកដល់វ៉ាងំណក់ហ្នឹងក៏ជួបពួកទាហានខ្មែរក្រហមយើងហ្នឹង នៅហ្នឹងគេហ្នឹងទៅហើយប្រពន្ធកូនមិនទាន់ឃើញទេ គាត់នៅប៉ៃលិននោះចេះតែទាក់ទងទៅ ។

វណ្ណៈ ចឹងអ៊ឹបានធ្វើដំណើររហូតដល់ជាយដែនហ្នឹងដល់ពេលណាទៅ?

ស៊ាន់ៈ មើលចុងខែ១២ឆ្នាំ១៩៧៩ ថ្ងៃដូចជា២៥ខែ១២ឆ្នាំ៧៩ ។

វណ្ណៈ អ៊ឹដល់ព្រំដែនខាងណា?

ស៊ាន់ៈ ព្រំដែនខាងមេទឹក ខាងខេត្តត្រាត អាហ្នឹងវានៅក្នុងតំបន់ខេត្តត្រាត ខាងពោធិសាត់ជាប់ ជាមួយខេត្តកោះកុងនៅព្រំប្រទល់ហ្នឹងឯងខាងថ្មដាអីហ្នឹងខ្ញុំមិនសូវស្គាល់ទេ ខ្ញុំនៅបានបួនយប់ប្រាំថ្ងៃហ្នឹង គេបញ្ជូនខ្ញុំមកហ្នឹង ។

វណ្ណៈ ចឹងនៅហ្នឹងរយៈពេលខ្លីទេ?

ស៊ាន់ៈ បាទ!យ៉ាងយូរមួយអាទិត្យមិនទាន់ដឹងថាធ្វើស្អីទេមិនទាន់ដឹងទេ ។

វណ្ណៈ ចឹងបានមួយអាទិត្យបញ្ជូនមកខាងអន្លង់វែងនេះវិញ?

ស៊ាន់៖ មិនមែនមកខាងអន្លង់វែងទេ ទៅខាងមុំបីនោះ ជិតខេត្តចំប៉ាសាក់នោះ ដំបូងនៅសុទ្ធតែ ព្រៃ អត់មានមនុស្សផងហ្នឹង ។

ដានី៖ ចឹងអ៊ំថាមកខាងរថភ្លើងវិញ រថភ្លើងដំបូងគេមានក្រសួងគេផ្សេងតើ?

ស៊ាន់៖ ខ្ញុំវាមិនបានដឹងទេ រឿងក្រសួងរឿងអី ។

ដានី៖ ពីព្រោះកាលហ្នឹងអាកាសចរណ៍ផ្សេងខាងរថភ្លើងផ្សេង ពេលក្រោយមកអ៊ំមានប្រសាសថាខាង តា វៃ គេឲ្យមកខាងរថភ្លើងវិញ?

ស៊ាន់៖ បាទ!ហើយមិនដឹងថា មេខាងរថភ្លើងហ្នឹងគេទៅណាទៅណីទេ ខ្ញុំក៏មិនដឹងដែរ ។

ដានី៖ ចឹងយើងមកគ្រប់គ្រងជំនួសគេ?

ស៊ាន់៖ មកគ្រប់គ្រងជំនួសគេចឹងទៅ ដូចថាដឹកជញ្ជូនខ្ញុំតាមរថភ្លើងដឹកជញ្ជូនចឹងទៅ ។

វណ្ណៈ អ៊ំមានស្គាល់អ្នកណាដែលនៅរស់ទេ ខាងបើករថភ្លើង?

ស៊ាន់៖ ចាំមិនបានទេ ។

វណ្ណៈ អ៊ំចេះបើកទេ កាលហ្នឹង?

ស៊ាន់៖ អត់ទេ ខ្ញុំមិនស្គាល់រថភ្លើងផង ចុះខ្ញុំនៅខាងជនបទ ខ្ញុំមិនដែលទាំងជិះផង ដល់មកចឹងទៅ យើងក្នុងនាមជាសមាជិកគេ ពេលប្រជុំអីយើងណែនាំបងប្អូនខំធ្វើឲ្យល្អទៅបម្រើជាតិឲ្យស្អាត ត្រឹមត្រូវទៅកុំធ្វើឲ្យខូចកុំធ្វើឲ្យមានវិបត្តិអីចឹងណាស់ និយាយចឹងអ្នកណាធ្វើអីធ្វើហ្នឹងទៅ ។

វណ្ណៈ ចឹង តា វៃ គាត់អ្នកគ្រប់គ្រង?

ស៊ាន់៖ គាត់អ្នកគ្រប់គ្រងពីលើ ។

វណ្ណៈ ចឹងឲ្យតែខាងរថភ្លើងគាត់?

ស៊ាន់៖ គាត់ គាត់នៅស្ថានីយហ្នឹង ។

ដានី៖ ចឹងនៅពេលដែលអ៊ំបានមកដល់ស្ទឹងមេទឹក កន្លែងថ្មដារអីហ្នឹងបានតែមួយអាទិត្យគេបញ្ជូន អ៊ំមក ខាងមុំបីទៀត?

ស៊ាន់៖ កាលហ្នឹងនៅមុំបី ។

ដានី៖ កាលហ្នឹងគេមានឲ្យអ៊ំនៅខាងកងទ័ពអីទេ?

ស៊ាន់៖ អត់ទេ ខ្ញុំមានគ្នាតែបីនាក់ គេឲ្យយកតែបីនាក់ទេមក ។

ដានី៖ ពីថ្មដាមក?

ស៊ាន់៖ បាទ!មានតែបីនាក់គត់ មកដល់ថាដូចជាអន្លង់អន្ទូចវាកំសត់ខ្លួននៅតាមព្រៃស្រាប់តែមួយខែ មានកម្លាំងគេមកពីឥសាន ។

ដានី៖ ចឹងអ៊ំទៅដល់មុនគេ?

សាន់ៈ ខ្ញុំទៅមុនគេ ។

ដានីៈ ចឹងពេលទៅដល់អឹមានឃើញពីណាមុនគេ?

សាន់ៈ ទៅដល់ដំបូងហ្នឹងអត់មានឃើញពីណាមុនទេ ឃើញតែស្អីទេនៅជាមួយតា សុន សេន ឈ្មោះ កែវ ឈ្មោះ កែវ ហ្នឹងគាត់ជាអ្នកបកប្រែជាមួយថៃអីហ្នឹង ។

ដានីៈ ចឹងមិនមែន តា ជា កែវទេ?

សាន់ៈ មិនមែនទេ តា ជា កែវ គាត់មិនទាន់មកពីខាងឥសានទេ ខ្ញុំមិនទាន់ស្គាល់គាត់ផង ។

វណ្ណៈ ចឹងកាលអឹទៅដល់ខាងមុំបីហ្នឹងឃើញថា សុន សេន នៅហ្នឹងដែលឬមួយអត់ទេ?

សាន់ៈ តា សុន សេន អត់មានទេ មានតែឈ្មោះ កែវ ហ្នឹងគេជាអ្នកទទួលកម្លាំងពីភូមិភាគឥសាន ខ្ញុំទៅហ្នឹងកម្លាំងគេឡើងមក ខ្ញុំក៏ឡើងមកខាង១០០២វិញ ។

ដានីៈ ចឹងដំបូងកន្លែងមុំបីហ្នឹងគេហៅ១០០១ ចឹងយ៉ាងម៉េចបានជាគេហៅ១០០១ចឹង?

សាន់ៈ កាលហ្នឹងខ្ញុំវាមិនយល់ដែលគេដាក់លេខដូចជា៥០៥ដូចជា១០០៣ដូចជា១០០២ដូច ជា១០០១ចឹង គេដាក់លេខច្រកៗហ្នឹង ។

ដានីៈ ចឹងអត់ដឹងថា ពីព្រោះយើងអាចថាមានមូលហេតុគេយ៉ាងម៉េចបានគេហៅ១០០១ដូច ជា ១០០២ដោយសារវាចេះដូចជា១០០១ដោយសារច្រកហ្នឹងវាយ៉ាងម៉េចមានចំណុចពិសេស យ៉ាងម៉េចបានជាគេដាក់ឈ្មោះចឹង?

សាន់ៈ អត់ដឹងដែរខ្ញុំ ។

ដានីៈ ដូចជាស្រុកត្រពាំងប្រាសាទ យ៉ាងម៉េចបានគេដាក់ឈ្មោះថា ត្រពាំងប្រាសាទ?

សាន់ៈ ត្រពាំងប្រាសាទវាមានត្រពាំងហើយមានប្រាសាទ ។

ដានីៈ ចឹងខ្ញុំចង់ដឹងចឹង ហើយ១០០១?

សាន់ៈ ១០០១អត់មានទេ គេដាក់លេខតែម្តង គេហៅតំបន់មុំបីព្រំប្រទល់ថៃ លាវ ខ្មែរ ហ្នឹង គេ ហៅមុំបី ។

ដានីៈ មុំបីហ្នឹង១០០១ហ្នឹង ទីតាំងវាលាតសន្ធឹងពីត្រឹមណាដល់ត្រឹមណា?

សាន់ៈ និយាយរួមទីតាំងវានៅខាងខេត្តឧបុណា ស្រុកណាមយឺន ហើយច្រកគេធ្វើចេញពីមួយ ផ្លូវ ស្រុកហ្នឹង ។

ដានីៈ ប៉ុន្តែមុំហ្នឹងទេឬក៏មានច្រើនកន្លែងដែរ ។

សាន់ៈ ១០០៣ហ្នឹងមានតែមួយកន្លែង១០០៣ហ្នឹង ។

ដានីៈ ១០០១?

សាន់: បាទ!១០០១មានតែមួយច្រកហ្នឹង ច្រកហ្នឹងគេទទួលកម្លាំងមកពីឥសានផងមកពីភូមិភាគកណ្តាលអីផង មកជួបគ្នានៅកន្លែងហ្នឹងបានគេចាត់ចែងទៅហើយ ។

ដានី: ពេលអ៊ីនៅហ្នឹងរហូតមានឃើញកម្លាំងគេមកដែលអត់?

សាន់: អត់ទេ ចាំមើលខ្ញុំនិយាយឲ្យអស់ ខ្ញុំនៅមិនបានយូរទេ បានប្រហែលជាមួយខែកម្លាំងគេឡើងមក ឡើងមកក៏គេបញ្ជូនខ្ញុំមកទៀតមកនៅ១០០២រាល់ថ្ងៃហ្នឹង ១០០២យើង ច្រកជុបរុនហ្នឹងនៅម្តុំ៤០គេហៅ៤០តាពោកយក្សអីចឹង ។

ដានី: ១០០២ហ្នឹងគេហៅជុបរុន?

សាន់: ជុបរុន ហ្នឹងក៏កន្លែង តា ម៉ុក គាត់ធ្វើដែរ ។

វណ្ណៈ ចឹងច្រក៤០?

សាន់: ៤០ហ្នឹងវាអត់មានច្រកទេ គេហៅតំបន់៤០វាលដងទង់ហ្នឹងណាស់ នៅក្រោយភូមិអូរស្មាយរាល់ថ្ងៃហ្នឹង ។

ដានី: ១០០២ហ្នឹងក្រែងនៅច្រកអានសេះ?

សាន់: អត់ទេ អានសេះវានៅខាងនោះទេ នៅជាប់ពី១០០១មក អានសេះខាងជាំក្សាន្តព្រះវិហារនោះ ។

ដានី: អាហ្នឹងមិនមែនច្រក១០០២ទេ?

សាន់: អត់ទេ អានសេះផ្សេង ។

ដានី: ចឹង១០០២មកខាងជុបរុននេះវិញទេ?

សាន់: បាទ!ខាងជុបរុន ។

ដានី: ជុបរុនតំបន់៤០អីនេះវិញទេ?

សាន់: បាទ!ហ្នឹងហើយ ។

ដានី: ចឹងអ៊ីមានប្រសាសមិញ ជុបរុន តំបន់៤០អីទៀតមិញនៅក្នុង១០០២ដែរ?

សាន់: មានតែវាលដងទង់ ៤០ហ្នឹងដងទង់ហើយ ដងទង់ក្រោយអូរស្មាយយើងនេះ ។

ដានី: ចឹងតាពោកយក្សមិញនោះ?

សាន់: អាហ្នឹងភ្នំគេចេះតែហៅជាក់ងារនៅក្នុងឆ្នាំ១៩៨០ ហ្នឹងខែ២ខ្ញុំឈប់នៅហើយលើភ្នំនេះ បាត់មុខខ្ញុំហើយ ។

ដានី: អ៊ីទៅខាងណាវិញ?

សាន់: គេរៀបចំមួយកងពល៦១២ មាន តា ហឿន ហ្នឹងគាត់នៅរាល់ថ្ងៃទេ ។

ដានី: ចឹងខែ២ឆ្នាំ១៩៨០បង្កើតកងពល?

សាន់: បង្កើតហ្នឹងមិនមែនខែ២ទេ បង្កើតហ្នឹងមុនកងពលរបស់ខ្ញុំហ្នឹងក៏មាន បង ហឿន គាត់ធ្វើប្រធានអីចឹងទៅណាស់ កាលនោះ ។

ដានី: ចឹងបង្កើតឆ្នាំ៧៩ឬ៨០ ?

សាន់: បង្កើតឆ្នាំ៨០ដាង ដល់ចឹងគេបំបែកកម្លាំងហ្នឹងពី៨០១ខ្លះមកណា គេឲ្យមកមួយវរៈមក មួយវរៈធំហ្នឹង មានឈ្មោះ អ៊ីម តែក្រោយមកគាត់ចូលទៅខាងប៉ារា ប៉ារាបាញ់ចោល បាត់ហើយ ។

ដានី: ឈ្មោះ អីគេ?

សាន់: ប្រធានខ្ញុំចាំមើលខ្ញុំនិយាយឲ្យអស់ ដល់ពេលគេបង្កើតកងពល៦១២ហ្នឹងវាមានមួយវរៈ ៦២ ហ្នឹងអគ្គភាពរបស់ខ្ញុំតែមានឈ្មោះ អ៊ីម ហ្នឹងគាត់ធ្វើប្រធានហើយក៏បានឡើងធ្វើអនុគេ ។

ដានី: អនុវរសេនាធំ?

សាន់: អនុវរសេនាធំហ្នឹងតែអត់បាននៅហ្នឹងទេ ចាត់តាំងហើយបញ្ជូនខ្ញុំទៅដើងទឹកនោះ ទៅនៅខាងទន្លេសាប ខ្ញុំនៅទន្លេសាបរហូត ខ្ញុំមិនបានសួរលើភ្នំទេ ខ្ញុំមិនសូវស្គាល់ទេ ។

ដានី: ចឹងកងពល៦១២ហ្នឹងមានប៉ុន្មានវរសេនាធំ?

សាន់: មានបី មាន៦១មាន៦២មាន៦៣ ។

ដានី: ហើយប្រធានកងពលឈ្មោះ?

សាន់: អ៊ិន ហឿន រាល់ថ្ងៃហ្នឹង អូស!ប្រធានកងពលហ្នឹងមិនមែន អ៊ិន ហឿន ទេ ឈ្មោះ ឈានកាតុលនៅបាត់ដំបងយើងរាល់ថ្ងៃ ។

ដានី: ឥឡូវគាត់នៅបាត់ដំបង?

សាន់: បាទ ។

ដានី: គាត់ធ្វើអីនៅបាត់ដំបងឥឡូវ?

សាន់: ខ្ញុំមិនបានដឹងដែរ តែគាត់ពីមុនជាប្រធានកងពលខ្ញុំហ្នឹង ហើយ អ៊ិន ហឿន គាត់អនុ ។

ដានី: ហើយវរសេនាធំ៦១ពីណាគេធ្វើប្រធាន?

សាន់: ឈ្មោះ យិន តែមិនដឹងជាទៅណាអស់ទេ បាត់អស់ហើយឈ្មោះ យិន មិនបានស្គាល់នាមត្រកូលទេ ។

ដានី: ចឹង៦២?

សាន់: ៦២ហ្នឹងឈ្មោះ យិន ជាប្រធាន ។

ដានី: ហើយអឹអនុ?

សាន់: ខ្ញុំអនុគ្រាន់តែរៀបចំហើយខ្ញុំទៅទន្លេ ។

ដានី៖ ចិន៦៣?

ស៊ាន់៖ ៦៣កាលហ្នឹងមិនដឹងជាពីណាទេ ភ្លេចឈ្មោះ៦៣ហ្នឹងមួយទៅខ្ញុំភ្លេចបាត់ហើយ ។

ដានី៖ ចិនមិនមែនពូ វ៉ាន់កុសល្យទេ?

ស៊ាន់៖ អត់ទេ ពូ វ៉ាន់កុសល្យ គាត់ផ្សេងទេ បង្កើតមួយកងពលផ្សេងពីមុនគាត់ទទួលខាង៦៣ ហ្នឹងដែរខ្ញុំមិនដឹងខ្ញុំមិនបានចាំកាលហ្នឹង ព្រោះចំកងហ្នឹងហើយគេបញ្ជូនខ្ញុំឲ្យទៅកាន់កងជើងទឹកខាងទន្លេសាប ។

ដានី៖ ចិនខាងទន្លេសាបហ្នឹងខាង៦២ទៅទាំងអស់ឬយ៉ាងម៉េច?

ស៊ាន់៖ អត់ទេ ខ្ញុំទៅតែ១៥០នាក់ទេ ចែកគ្នាទៅ ហើយ អ៊ុម ហ្នឹងគាត់ទីងហៀនចាត់តាំងឲ្យ ទៅចិនទៅដូចជាប្រណែនរឿងលុយរឿងកាក់មាសប្រាក់ដែលយកចុះទៅក្រោមទៅធ្វើ ការងារជាមួយប្រជាជនចិន ពួកខ្ញុំពួកឃោសនា បីកុំបីកសាងនោះ អាវុធបីយ៉ាង សេដ្ឋ កិច្ចជីវភាព ។

ដានី៖ បីកុំបីកសាង?

ស៊ាន់៖ បាទ!បីកុំបីកសាង បីអាទី១ហ្នឹងកុំឲ្យកាប់សម្លាប់ប្រជាជនអីចិនណាស់ បីកសាង កសាងកម្លាំងផ្ទៃក្នុងប្រជាជន ដូចថាប្រមូលកម្លាំងអ្នកណាគេថាស្រឡាញ់អ្នកស្នេហាជាតិចិនទៅខ្មែរក្រហមឲ្យចូលមកចិនទៅ យើងឲ្យលុយកាក់សារុងចិនទៅ ចាត់តាំងជាស្នូរកអន្តរអី ចិនខ្ញុំទៅនៅខាងហ្នឹង ខ្ញុំទៅនៅតាំងពីឆ្នាំ១៩៨២ដល់៨៨ខ្ញុំឈឺឡើងមកវិញដេកពេទ្យ បណ្តោយឈប់ធ្វើទាហានអីទាំងអស់ ។

ដានី៖ ខ្ញុំចង់ដឹងមួយសារទៀតទាក់ទងរឿងបីកុំ ទីមួយកុំកាប់សម្លាប់?

ស៊ាន់៖ បីកុំហ្នឹង កុំកាប់សម្លាប់ កុំយកទ្រព្យរបស់ប្រជាជនអីណា កុំឲ្យប៉ះពាល់រឿងប្រជាជនកូនប្រពន្ធគេអីហ្នឹងគ្រប់យ៉ាង ។

ដានី៖ ចិនបីកសាងមានអីទៅ?

ស៊ាន់៖ បីកសាង សាងកម្លាំង កសាងកម្លាំង ចង់និយាយថា កាលពីមុនគេនិយាយកសាង កម្លាំងស្នូមិនចិន ទាញកម្លាំងកសាងទាហាន កសាងកម្លាំងផ្ទៃក្នុងប្រជាជនឲ្យផ្តាច់ពី ហ៊ុន សែន ចិនឲ្យគាំទ្រ ប្រមូលកម្លាំងខាងសត្រូវ ។

ដានី៖ ចិនទើបបានតែពីរ?

ស៊ាន់៖ ហើយឯកកោរទាហានអត់ឲ្យវាយទេ ទាហានកម្ពុជាអត់មានឲ្យវាយទេ វាយតែយួនបើ យួនវាយហើយកម្លាំងយោធាខាង ហ៊ុន សែន ហ្នឹងឲ្យយើងខំកសាងទំនាក់ទំនងឲ្យលុយ កាក់ចិនទៅទិញគ្រាប់រំសេវជួយរក បើមិនទាហានមិនអាចលក់ឲ្យយើងបានទេ ។

ដានី៖ ពាក្យហ្នឹងចេញមកពីណាបីកុំ បីកសាងហ្នឹង?

ស៊ាន់៖ ទេ វាមានឯកសារគេចឹងតែម្តង រៀនមកចឹង ។

ដានី៖ អឺមាននៅសេសសល់ឯកសារហ្នឹងទេ?

ស៊ាន់៖ អត់ទេ អូនស្ទីបន្តិចក៏គ្មានដែរ ។

ដានី៖ មើលគេរៀនម៉េចមិញ អឺមានប្រសាសនមិញ បីកុំបីកសាង?

ស៊ាន់៖ អាវុធបីយ៉ាងហ្នឹង ។

ដានី៖ អាវុធបីយ៉ាងម៉េច?

ស៊ាន់៖ មានសេដ្ឋកិច្ច ជីវភាពសេដ្ឋកិច្ច ជីវភាពហ្នឹងចង់និយាយថា ខំជម្រុញឲ្យប្រជាជនខំកសាងសេដ្ឋកិច្ចជីវភាពមានបុសមានគលដាំដុះចិញ្ចឹមចឹងទៅណា កុំជឿគេឃោសនាអីចេះចុះ ។

ដានី៖ អាវុធបីយ៉ាងគឺកសាងជីវភាព?

ស៊ាន់៖ សេដ្ឋកិច្ច ជីវភាព ។

វណ្ណៈ សេដ្ឋកិច្ច ជីវភាពមានតែពីរហ្នឹង?

ស៊ាន់៖ ចុះអាវុធបីយ៉ាង ចុះខ្ញុំថាមួយបីកុំ បីកុំមានន័យថាកុំឲ្យធ្វើអំពើអាក្រក់ខ្ញុំនិយាយតែមួយហ្នឹងបានហើយ ហើយបីកសាង គឺយើងកសាងកម្លាំង កម្លាំងប្រជាជនពី ហ៊ុន សែន ហើយមួយទៀតបើគេជាយុវជនបើគេធ្វើទាហានឲ្យចូលមកខាងយើង បីកសាងមួយទៀត វាចូលក្នុងអាវុធបីយ៉ាងហើយណា បីកសាងមួយទៀត បំផុសប្រជាជនឲ្យធ្វើ សេដ្ឋកិច្ចជីវភាពរកត្រីតាមទន្លេដូចគេរាល់ថ្ងៃចឹង រកត្រីអីយើងការពារ ការពារពីពួក ឈ្លួញឲ្យប្រជាជនយើងចូលរកទៅ គាត់ចិញ្ចឹមយើងខ្លះផង យើងការពារគាត់ ជំនាន់ហ្នឹងចឹងទេ ខ្ញុំមិនលាក់ទេខ្ញុំនិយាយត្រង់ ។

ដានី៖ ចឹងយ៉ាងម៉េចទៀតទៅ អឺថាប្រធានអឺឈ្មោះ អ៊ុម ប្រណែនអីនោះ?

ស៊ាន់៖ គាត់ប្រណែនរឿងការចាត់តាំងអីមកក្រោម ធម្មតាទេ មកក្រោមគេឲ្យលុយ ខ្ញុំមកមួយ ជើងមួយឆ្នាំពីរឆ្នាំឡើងទៅវិញគេឲ្យលុយច្រើន ចង់និយាយថា មួយសែនបាតអីចឹងទៅ ពីរបីពាន់ដុល្លាចឹងទៅ មាសកន្លះគីឡូចឹងទៅ ។

វណ្ណៈ ចឹងមានមាសដែរ?

ស៊ាន់៖ បាទ!មាស មានមាសអីហ្នឹងយកទៅដូរជាទូកចឹងណាស់ ដូរជាម៉ាស៊ីនអី គាត់ដូរអត់មាន ថ្នឹងទេ ដូរជាអង្ករជួយប្រជាជន ចឹងបាននិយាយឲ្យវែងបន្តិចចុះ មកពីខ្ញុំនៅក្រដាងគេ មកពីខ្ញុំមិនចេះលួច ខ្ញុំមនុស្សត្រង់ ត្រង់តែម្តងមិនយកទេរបស់គេ របស់អ្នកដឹកនាំថ្នាក់ លើសល់អត់យកទេ ឲ្យទាហានឲ្យអីអស់ទៅ ខ្ញុំចឹងទេ ជីវិតខ្ញុំ រកស៊ីរាល់ថ្ងៃដោយកម្លាំង មានប្រាក់ខែបន្តិចបន្តិច ។

ដានី៖ អឺទៅខាងទន្លេសាបទៅម្តុំណាទៅ?

សំាន់ៈ ខ្ញុំមុខសញ្ញាខ្ញុំក្រោមកំពង់ធំ ម៉ាជួរផាត់សារាយណ៍ ទៅទល់គ្នាមុខកំពូល ។

វណ្ណៈ ចឹងមុខកំពូលខេត្តកណ្តាលនោះ?

សំាន់ៈ បាទ ។

ដានីៈ ពីផាត់សារាយណ៍ខេត្តកំពង់ធំនេះ ពីទន្លេសាបទៅ?

សំាន់ៈ បាទ ។

វណ្ណៈ ចល័តរហូត?

សំាន់ៈ បាទ!ចល័តរហូតទៅមួយយប់ចឹងទៅបកមកវិញ អត់ហ៊ាននៅទេ សែងទូកសែងអី ។

ដានីៈ កាលហ្នឹងអឹដាក់ឈ្មោះ សំាន់ឬឈ្មោះ សាម?

សំាន់ៈ ឈ្មោះ សាម កាលនោះ អ្នកស្រុកស្គាល់ខ្ញុំតែឈ្មោះ សាម ទេ ។

វណ្ណៈ ចឹងឈ្មោះ សំាន់?

សំាន់ៈ ឈ្មោះ ដើមកំណើតពីឪពុកម្តាយមក ។

វណ្ណៈ ចឹងនៅសម័យតស៊ូនេះដាក់ឈ្មោះ សាម ទៅ?

សំាន់ៈ បាទ!សាមហ្នឹងដល់ហើយខ្ញុំដាក់ឈ្មោះ ដើម ខ្ញុំវិញទៅ កាលសមាហរណ៍កម្ម ។

ដានីៈ ចឹងមានវរសេនាធំណានៅខាងព្រះវិហារ?

សំាន់ៈ ពិបាកណាស់ បង ហឿន នៅខាងព្រំដែន ក្រោយមកគាត់នៅខាងព្រំដែន ហើយខាងវរសេនាធំហ្នឹង ពួកណាទេ ធ្វើប្រធានខ្លះ ព្រោះបែកបាក់គ្នាហើយ ខ្ញុំទៅខាងទន្លេហើយ ខ្ញុំទៅខាងទន្លេហ្នឹងគេមិនដាក់ថា វរសេនាធំទេ គេហៅ៦២៦កងពល ឯកងពលហ្នឹងចង់ និយាយថា ថ្នាក់លើគេបញ្ជា គេចាត់ចែងមិនបាច់កងពលណាទៅគ្រប់គ្រងទេ ហើយរាយការណ៍ ត្រង់មក ។

ដានីៈ ត្រង់ទៅខាងណាវិញ?

សំាន់ៈ ត្រង់មកជាមួយ តា ម៉ុក កាលហ្នឹងយើងប្រើទូរលេខវ៉ាកាណូចេះរវៃទៅតិចៗៗតាហ្នឹងឯង ។

ដានីៈ ប៉ុន្មានខែបានយើងឡើងមកម្តង?

សំាន់ៈ ខ្ញុំអត់មានខែទេ ពីរឆ្នាំទៀង បើមានខ្វះលុយរាយការណ៍មកគេទៅ គេមានបញ្ជូននិរសា នាំយកទៅឲ្យទៅ យើងចាត់ចែងទៅកសាងកម្លាំង គេអត់មានសួររឿងវាយទេខាងខ្ញុំ គេសួរថាកសាងកម្លាំងបានប៉ុន្មាន កម្លាំងទាហានរឹកប៉ុន្មាន កម្លាំងប្រជាជនមកខាងខ្មែរក្រហមហ្នឹងប៉ុន្មាន ស្អប់ ហ៊ុន សែន ប៉ុន្មាន ចឹងណាស់ យើងរាយកាណ៍តាមតែយើង ឃើញដាក់ស្ទែងទៅ ។

ដានីៈ កង៦២៦កងពល?

ស៊ាន់: បាទ!កងឯករាជ្យ ក្រោយមកដល់ខែ៧ឆ្នាំ៨៥ បានគេចាត់តាំងកងពល កងពល៧៨៥ មាន ឈ្មោះ វឿន មួយនៅរាល់ថ្ងៃនេះ គាត់ធ្វើប្រធានកងពល ។

ដានី: ដល់ពេលកងពល៧៨៥នេះ កើតខែ៧ឆ្នាំ១៩៨៥?

ស៊ាន់: បាទ!ខ្ញុំក៏នៅក្នុងកងពលហ្នឹងជាមួយគេដែរ ។

ដានី: ចឹងកងពល៦១២ហ្នឹង យ៉ាងម៉េចបានគេដាក់កងពល៦១២?

ស៊ាន់: ខ្ញុំមិនបានដឹងដែរ បើ៧៨៥ហ្នឹងខ្ញុំចាំតែម្តង ខែ៧ឆ្នាំ១៩៨៥ គេរៀបចំកងពលបញ្ចូល គ្នា កាលហ្នឹងវាមាន៦២ខ្ញុំហ្នឹង មាន៥៥ ហើយកងឯករាជ្យរបស់ តា តេង ឥឡូវ គាត់ស្លាប់បាត់ហើយ តា តេង តា ប៉ាន អ្នកកំពង់ឆ្នាំង គាត់ស្លាប់អស់ហើយ បីវរៈ ហ្នឹងគេប្រមូលចូលគ្នាមកបានមួយកងពល៧៨៥ ហើយឈ្មោះ វឿន រាល់ថ្ងៃហ្នឹងគាត់ នៅកងពលលេខ៨ ហ្នឹង គាត់ធ្វើប្រធានកងពល គាត់មានសត្វល្អិតនៅក្នុងខួរក្បាលគាត់ ចេះតែឡេឡឺទៅ ។

វណ្ណៈ: ឥឡូវហ្នឹង?

ស៊ាន់: ឥឡូវហ្នឹងមើលជាហើយ គាត់ទៅពេទ្យនៅភ្នំពេញគេជួយមើល ពេទ្យខាងយោធានោះ គាត់ នៅធ្វើទាហាននោះ ។

ដានី: បាទ!ចឹងមានបីវរសេនាធំ មាន៦២ មាន៥៥?

ស៊ាន់: ៦២មាន៥៥និងកងបង តេង ហ្នឹងមិនជាគេដាក់៦០ប៉ុន្មានទេ វាមិនបាបចាំទៀត គឺ មានបី កាលហ្នឹង បង តេង គាត់ធ្វើប្រធាន ។

ដានី: ចឹងកាលហ្នឹងប្រធានកងពលឈ្មោះ តា វឿន?

ស៊ាន់: បាទ ។

ដានី: ពីណាជាអនុគាត់?

ស៊ាន់: អនុគាត់ តា គេម ឈ្មោះ គេម ហ្នឹងងាប់បាត់ហើយ ងាប់នៅសារិននោះ ហើយមាន សមាជិកទាំងអស់មួយកងខ្ញុំអីហ្នឹង ។

ដានី: ដល់ចឹងអ៊ំបានឡើងប្រធានហើយ?

ស៊ាន់: អត់មានទេ គ្មានប្រធានទេកាលនោះ គ្រាន់ថាគេបូកគ្នា បូកកងហ្នឹងបូកបញ្ចូលគ្នាហើយ វរសេនាធំប្រធានហ្នឹងមិនទាន់មានទេ នៅទេក៏ខ្ញុំឈឺដកខ្ញុំមកលើវិញមក ទៅដេកពេទ្យ សារិន ជិតមួយឆ្នាំ ។

ដានី: ចឹងតាំងពីឆ្នាំ៨៥ហ្នឹង?

ស៊ាន់: អត់ទេ ឆ្នាំ៨៧-៨៨ ព្រោះខ្ញុំឈឺតាំងពី៨៥មក ហើយយើងមកទំមើលលើភ្នំហ្នឹងគេ មិន ធ្វើអីទេ ទៅពេទ្យព្យាបាលចេះតែមើលចឹងទៅ ព្យាបាលមិនជាក៏គេបញ្ជូនទៅដេក ពេទ្យទៅ ។

ដានី៖ ឈើអីគេគ្រូនចាញ់?

ស៊ាន់៖ ខ្ញុំអត់ទេ ដំបៅពោះវៀន ហើយរលៀកក្រពះ គ្រូនចាញ់ប៉ូកផ្សំ ។

ដានី៖ ចឹងឈឺតាំងពី៨៥មក?

ស៊ាន់៖ ឈឺតាំងពី៨៥មក តែ៨៨បានគេបញ្ជូនខ្ញុំចេញទៅពេទ្យហើយចេញមកវិញឈប់ធ្វើ រហូតអត់មានធ្វើទាហានអីទេ ។

ដានី៖ ដល់ឆ្នាំណាបានអ៊ំចេញមកវិញ ឆ្នាំណាដែលដាច់?

ស៊ាន់៖ ខ្ញុំការពិតជាមិនដាច់ទេ ដាដាច់ដល់ឆ្នាំ៩២-៩៣នោះ អាហ្នឹងខ្ញុំដាហើយ តែខ្ញុំជាខ្ញុំមិនបានធ្វើទាហានវិញទេ ខ្ញុំនៅក្រោយហ្នឹងនៅប្រកដុបរុនយើងរាល់ថ្ងៃហ្នឹង ហើយធ្វើសមាហរណ៍កម្មជាមួយ ហ៊ុន សែន ទៅវាមានទំនាស់គ្នាប៉ែកខាងលិចនិងប៉ែកខាងកើត ពួកខ្ញុំនេះទៅប៉ែកខាងកើត ប៉ែកខាងកើតគេចង់និយាយជាប៉ែកខាង ប៉ុល ពត ខាងលិចប៉ែក តា ម៉ុក ហើយយើងមិនដឹងថា ប៉ុល ពត តា ម៉ុក អីទេ កាលហ្នឹង យើងដឹងថាធ្វើឲ្យ ត្រឹមត្រូវឲ្យល្អចឹងទៅណាស់ ដល់ចឹងទៅពួកខ្ញុំក៏នាំគ្នាផ្តាច់ខ្លួនបណ្តោយទៅ បដិសេធប៉ែកខាងលិចហ្នឹងមាន តា ជុំ ទេ គាត់ដឹកនាំរត់ចូលជាមួយរដ្ឋាភិបាល គាត់មកវិញគាត់ បាចខិតប័ណ្ណតាមយន្តហោះប្រមូលកម្លាំងទៅ កម្លាំងពួកខាងខ្ញុំក៏នាំគ្នារត់ទៅខាងទំនប់ដាច់ទៅចឹងទៅ ហើយក៏ចូលកម្លាំងជាមួយពួក ស្រី ឌឹក យើងហ្នឹងវាយពួកខាងលិចវិញ វាយគ្នាឯងហ្នឹង វាយគ្នាឯងហ្នឹង ខ្ញុំអត់ទេខ្ញុំគេឲ្យគ្រប់គ្រងកម្លាំងប្រពន្ធទាហាននៅខាងក្រោយ ។

ដានី៖ ចឹងអ៊ំតាំងពី៨៥មកអ៊ំដាច់ចេញពីកងពលហើយ?

ស៊ាន់៖ ដាច់ចេញហើយ ។

ដានី៖ ចឹងកាលឡើងមកឆ្នាំ៨៥អ៊ំឡើងមកនៅណាវិញ?

ស៊ាន់៖ ដើរមកតាមយើងស្រុកស្មោងនេះ ។

ដានី៖ ប៉ុន្តែមកនៅណាវិញ?

ស៊ាន់៖ មកនៅលើភ្នំដងរែក ។

ដានី៖ កាលមកប្រកអីគេតំបន់អីគេវិញទៅ?

ស៊ាន់៖ តំបន់ដែលខ្ញុំនៅហ្នឹងគេហៅតំបន់ដាំស្វា ស្រុកឃុនហាន ខេត្តស៊ីសាកេត ស្រុកថៃហ្នឹង អាហ្នឹងគេសុទ្ធទិញដី ជួលអីហ្នឹង ។

វណ្ណៈ ចឹងដាំស្វានៅក្នុងដីណា?

ស៊ាន់៖ នៅក្នុងដីថៃ ថៃទាំងអស់ ។

ដានី៖ នៅក្នុង១០០០ប៉ុន្មាន?

សាន់៖ កាលហ្នឹងនៅក្នុងក្របខ័ណ្ឌ១០០៣ ។

ដានី៖ នៅ១០០៣ចេញពី១០០២ទៀត?

សាន់៖ កាលហ្នឹង១០០២ឡេលប់ហើយ ។

ដានី៖ ១០០២គេលប់ឆ្នាំណា?

សាន់៖ ខ្ញុំមិនបានចាំឆ្នាំទេ ដល់ខ្ញុំឡើងមកនៅជាំស្វាហ្នឹងគេដាក់១០០៣ទាំងអស់ ។

ដានី៖ មូលដ្ឋានរបស់១០០៣នៅម្តុំណាទៅ ទីតាំងធំ?

សាន់៖ ទីតាំងធំជាងគេនៅជុបរុនយើងនេះ ។

ដានី៖ ជុបរុន នៅកន្លែង១០០២ហ្នឹង?

សាន់៖ កន្លែង១០០២ហ្នឹង ដល់ហើយគេលប់ចោលអស់ហើយលែងមាន១០០២មាន១០ ០១អីទេ នៅតែ១០០៣មួយគត់ ហើយ១០០១យកកន្លែងតំបន់អានសេះហ្នឹងយកជា ច្រកមួយ ព្រោះថៃវាដាក់ច្រកៗចឹង ហើយ១០០៣ហ្នឹងចាប់តាំងពីជាំសាទាំយើងមក រហូតមក ។

ដានី៖ ចឹងខ្ញុំយល់ហើយចឹង ដំបូងបំផុតដែលកកើតមុនគេមានតែតំបន់មុំបីហ្នឹង?

សាន់៖ បាទ ។

ដានី៖ ដូចជាមេធំៗ ដូចជា តា សុន សេន តា ម៉ុក អី គាត់ទៅជួបជុំគ្នានៅកន្លែង១០០១ ហ្នឹង ទេ?

សាន់៖ ដំបូង ។

ដានី៖ បាទ!ដំបូងបំផុតដែលអឺថាទៅមុនគេហ្នឹង?

សាន់៖ មិនមែនទេ គេហៅ៨០៨ ដែលខ្ញុំមកដំបូងបំផុត៨០៨ ។

ដានី៖ ៨០៨នៅណា?

សាន់៖ ៨០៨នៅក្បាលអូរអង្រែយើងនេះខាងលិចជាំ ។

ដានី៖ អូរអង្រែនៅខាងអន្លង់វែងហ្នឹង?

សាន់៖ បាទ ។

ដានី៖ អាហ្នឹងដំបូងបំផុត៨០៨?

សាន់៖ បាទ!គេដាក់ឈ្មោះ៨០៨ខ្ញុំក៏មិនដឹងដែរ ខ្ញុំក៏មិនយល់ដែរ ។

ដានី៖ ពីណាគេមកដល់ដំបូងនៅហ្នឹង?

សាន់៖ ដំបូងកាលហ្នឹង តា ម៉ុក គាត់នៅហ្នឹង គាត់ពីថ្មដាមកគាត់មក៨០៨នៅហ្នឹងគាត់រៀប ចំមួយ កន្លែង ។

ដានី៖ បាទ ។

ស៊ាន់៖ គាត់មកនៅហ្នឹងបានប៉ុន្មានខែ បញ្ជូនខ្ញុំទៅរហូតដល់មុំបីហ្នឹង បញ្ជូនអត់មានកម្លាំងទេ ទៅត្រួសត្រាយឲ្យគេតែម្តង ទៅចាំទទួលកម្លាំងអីចឹង ។

ដានី៖ ចឹងដំបូងបំផុតគេហៅ៨០៨ កន្លែងអូរអន្ទ្រេ?

ស៊ាន់៖ ហ្នឹងហើយក្បាលអូរអន្ទ្រេហ្នឹង ។

ដានី៖ ដល់ពេលមានក្បាលអូរអន្ទ្រេហ្នឹងហើយ បានបញ្ជូនកម្លាំងទៅមុំបីទៅត្រួសត្រាយអី?

ស៊ាន់៖ បាទ!កម្លាំងប្រជាជនមកពីណាពីណីគេដាក់នៅហ្នឹងឯង ហេវបាយហើយនិយាយលែង ចង់កើតវិលមុខ ។

ដានី៖ ចឹងពីសាបាយសិនទៅ ។

ស៊ាន់៖ បាទ ។

## ០០:៥៥:០១“ភាគទី២”

ដានី៖ ចឹងអ៊ំហ្នឹងខ្ញុំដល់កន្លែងអូរអន្ទ្រេកន្លែង៨០៨?

ស៊ាន់៖ បាទ!កន្លែងហ្នឹង សូរ ហុង គាត់នៅ ។

ដានី៖ ចឹងដំបូងបំផុត?

ស៊ាន់៖ ដំបូងបំផុតខ្ញុំមកជួប សូរ ហុង ហ្នឹងឯង ។

ដានី៖ នៅកន្លែង៨០៨អូរអន្ទ្រេហ្នឹង?

ស៊ាន់៖ បាទ!គាត់ទទួលភ្ញៀវបរទេសគេ សូរ ហុង គាត់នៅ ខ្ញុំមិនស្គាល់ទេ ប៉ុន្តែគាត់ដឹកមកគេ ថានេះលោក សូរ ហុង គាត់ប្រចាំនៅ៨០៨ហ្នឹង សម្រាប់ចាត់ចែងកម្លាំងដែលមកពី នេះពីនោះអីចឹង ។

ដានី៖ ចឹងតា ម៉ុក គាត់មាននៅហ្នឹងដែលអត់?

ស៊ាន់៖ តា ម៉ុក គាត់អត់ដឹងទេ គាត់នៅលិចនោះទេ ។

ដានី៖ អត់ទាន់ឃើញទេ?

ស៊ាន់៖ អត់ទេ អត់មកទេ កាលខ្ញុំមកហ្នឹង តា ម៉ុក នៅគេហៅចម្ការស្រូវហ្នឹងដូចជាថ្មដានោះ ណាស់ជាប់កោះកុងខេត្តត្រាត ហ្នឹងហើយគេហៅចម្ការស្រូវ ខ្ញុំឡើងមកតាមភ្នំក្រវ៉ាញ់ អីយើងហ្នឹងខិវ៉ាល់អីហ្នឹង រួចហើយបានដឹកខ្ញុំពីហ្នឹងចេញមកខាងមុំបី នេះក៏មិនទាន់មានដែរ ។

ដានី៖ ចឹងកាលអ៊ំទៅដល់មុំបីអត់ទាន់មានឃើញ?

ស៊ាន់៖ អត់មានទេ ព្រៃសុទ្ធ ។

ដានី៖ ប៉ុន្តែ តាៗ ជាអ្នកដឹកនាំអត់ឃើញទេ?

សាន់៖ បាទ!អត់មានទេ មានតែលោក កែវ ហ្នឹងទេ លោក កែវ ហ្នឹង គាត់ថានៅជាមួយតា សុន សេន ខ្ញុំក៏មិនដែលស្គាល់ដែរ គាត់ជាជនជាតិលាវអីហ្នឹង ។

ដានី៖ តែអ៊ីថា ឡើងគាត់មកដឹបូងចំ៨០៨?

សាន់៖ បាទ!ចូល នៅហ្នឹង ។

ដានី៖ ចូលហ្នឹងហើយពីណាជាអ្នកចាត់ចែកអ៊ីឲ្យទៅ?

សាន់៖ ទេ ខ្ញុំអ្នកចាត់ចែងហ្នឹងទំនងថា អានេះវាតៗគ្នា អ្នកចាត់ការហ្នឹង បង ហុង គាត់ថា ថ្នាក់លើឲ្យបងទៅមុំបីសម្រាប់ទទួលកម្លាំង ខ្ញុំសួរថាពីណានៅ គេថាមិនដឹងពីណានៅទេ ទៅៗគង់តែឃើញទេ ហើយអត់មានទីតាំងទេ យើងស្ការព្រៃសម្រាប់ចងអង្រឹងនៅ ។

ដានី៖ ដល់ពេលអ៊ីទៅហ្នឹងបានតែមួយខែទេ?

សាន់៖ ដូចជាមិនដល់មួយខែផង ប្រហែលជាពីរអាទិត្យជាងប៉ុណ្ណឹង ក៏កម្លាំងគេមកក៏តាម៉ុក គាត់មកដែរ ។

ដានី៖ ឃើញ តាម៉ុក នៅហ្នឹងដែរ?

សាន់៖ បាទ!គាត់មកហ្នឹងឃើញគាត់ជិះឡានមកហ្នឹង គាត់ថាឯងបកទៅលិចវិញទៅ ទៅនៅជា មួយលោក ឃី លោក ឃី ហ្នឹងគាត់ទៅនៅលិចដែរ លោក ឃី ហ្នឹងគាត់ដឹកនាំកម្លាំង ស្រីៗទេណាស់ ហើយមានទាហានអី ខ្ញុំមកនៅជាមួយលោក ឃី ហ្នឹងគ្រប់គ្រងពួក ស្រីៗដឹកជញ្ជូនហ្នឹង ហ្នឹងសម័យនោះណាស់ ដល់ក្រោយមកបានគេរៀបចំកងពល៦១២ ហ្នឹងបានគាត់ឲ្យខ្ញុំមករស់នៅក្នុងកងពល៦១២ហ្នឹង មិនមែនធ្វើជាកងពលទេ មិនមែនធ្វើជាវរសេនាធំទេ មកនៅជាមួយកងពល នៅមន្ទីរកងពល ។

ដានី៖ ពីណាគេឲ្យអ៊ីមកនៅ?

សាន់៖ តា ម៉ុក កាលនោះ ។

ដានី៖ ចឹងឈ្មោះ ឃី ហ្នឹង?

សាន់៖ ឃី ហ្នឹងគាត់នៅ៨០១ តែគាត់ធ្វើការងារអីខ្ញុំមិនបានដឹងទេ កាលនោះ ។

ដានី៖ តែ តា ម៉ុក ឲ្យអ៊ីនៅកន្លែងមុំបីហ្នឹង ថាឲ្យមកខាងលិចវិញមកណាទៅ?

សាន់៖ មកជាមួយ ឃី ហ្នឹងមកនៅយើងម្តុំថ្មដា ដងទង់ហ្នឹងខ្ញុំនិយាយ៨០ហ្នឹង ។

ដានី៖ កន្លែង៨០នៅជុបរុនហ្នឹង?

សាន់៖ មិនមែនទេ ខាងលិចហ្នឹង ក្រោយអូរស្វាយ យើងទៅហ្នឹងដឹងថាឃុំអូរស្វាយហ្នឹងវាមានវាលដងទង់ពួកទៅរកក្រញូងអីគេទៅស្នាក់នៅហ្នឹងមកនៅហ្នឹង ។

ដានី៖ មកនៅហ្នឹងកន្លែងអូរស្វាយស្រុកត្រពាំងប្រាសាទយើងហ្នឹង?

សាន់: បាទ!ហ្នឹងឯង ។

ដានី: ពេលហ្នឹងតាម៉ុក គាត់ជិះមកដល់មុំបីហ្នឹងគាត់ទៅណាទៀតទៅ?

សាន់: អត់ដឹងទេ មិនបានដឹង ព្រោះគេថ្នាក់លើ គេទៅណាមកណាគេមិនអាចឲ្យយើងដឹងទេ ព្រោះគេតាមឡានរហូត ឡានមានពួកថៃពួកអីនាំផ្លូវចឹងថៃហ្នឹងគេហៅ "ឆប" ឆ ប ហ្នឹងសម្រាប់ទទួលខុសត្រូវខ្មែរក្រហមហ្នឹង មេកូនអីគេឲ្យជូនទៅណាជូនទៅតែម្តង លុយ កាក់អីយើងអត់ដឹងទេ ។

ដានី: ចឹង១០០១-១០០២-១០០៣ហ្នឹងមិនមែនកើតដំណាលគ្នាទេ?

សាន់: អត់ទេ ។

ដានី: បើតាមអ៊ីដឹងគេបង្កើតយ៉ាងម៉េច?

សាន់: ខ្ញុំអារឿង១០០១-១០០២-១០០៣មិនជាកើតយ៉ាងម៉េចដែរ ប៉ុន្តែខ្ញុំមកដល់ដំបូង ពីខេត្តត្រាតហ្នឹងមក ខ្ញុំមកតែបីនាក់ទេ ។

ដានី: មានពីណាខ្លះដែរ?

សាន់: ស្លាប់អស់ហើយ អស់ទាំងអស់រលីងតែម្តង ។

ដានី: ឈ្មោះ អីទៅ?

សាន់: អា សើ មួយវាទៅស្រុកបាត់ហើយក្មេង អាយុក្មេងទេ អាមួយទៀតឈ្មោះ ខេង ស្លាប់ដែលនៅខេត្តស្វាយរៀង ស្លាប់ទាំងអស់តែម្តងទាំងកូនទាំងប្រពន្ធអី ។

ដានី: និយាយទៅអ៊ីមកពីខេត្តត្រាតមកពីខែប៉ុន្មានឆ្នាំណាទៅ?

សាន់: ថ្ងៃទី១ឆ្នាំ១៩៨០ហ្នឹងតែម្តង ។

ដានី: ចឹងយើងថ្ងៃទី៧មករាឆ្នាំ១៩៧៩ ចឹង១២ខែបានដល់ខេត្តត្រាត?

សាន់: ចុះនៅក្នុងព្រៃនោះ យើងរត់មកនៅទិវ៉ាល់នោះ ហើយមានបានដឹងថាគេមកត្រាតអីអត់ មានបានដឹងទេ ទាល់អ្នកដែលគេនៅព្រំដែនចឹងគេចុះមកតាមកម្លាំង របៀបថាគេដើរប្រមូលកម្លាំងសេសសល់ត្រង់ណាគេនាំមក នាំមកហ្នឹងគ្រាន់រត់ឆាប់តាមផ្លូវរាប់ម៉ឺនអត់មាន បាយ ។

ដានី: ចឹងដល់ពេលឆ្នាំ៨០ហ្នឹង អ៊ីចេញពីត្រាតមកមានគ្នាតែបីនាក់?

សាន់: បាទ ។

ដានី: បីនាក់ឬមួយបីគ្រួសារ?

សាន់: អត់មានគ្រួសារទេ មានបីនាក់ មានខ្ញុំមានយុវជនពីរនាក់ជាមួយខ្ញុំ ។

ដានី: ពីណាជាអ្នកបញ្ជាអ៊ីមកខាងហ្នឹង?

ស៊ាន់៖ អ្នកចាត់ចែងខ្ញុំមិនបានដឹងដែរ ថា តាឲ្យឯងទៅនៅកើតទៅ ព្រោះឯងអត់មានទ័ពនិងគេ ទេ ខ្ញុំអត់មានទ័ពទេ អស់រលីងហើយ អស់ពីខ្លួនហើយកាលនោះ គាត់ក៏ឲ្យមកទៅណាស់ កាលហ្នឹង ។

ដានី៖ ដើរតាមដីខ្មែរមកឬដីថៃ?

ស៊ាន់៖ អត់ទេ ដីថៃ ថៃជូនទៀតពួក ឆ ប៉ី ហ្នឹងគេជាអ្នកជូនគេឲ្យលុយ១០០០បាតមិនដឹងថា ចាយស្អីផង អត់ចេះចាយ ។

ដានី៖ ចឹងថា តា ឲ្យមកហ្នឹង បើតាមអឹស្មានតា ណា?

ស៊ាន់៖ កាលហ្នឹងអ្នករៀបចំហ្នឹងយើងមិនទាន់ស្គាល់ ប៉ុល ពត ទេ យើងស្គាល់តាម៉ុក ហើយ អ្នកខាងក្រោមដូចជា តាវ៉ែន អីចឹង ខ្មោច តាវ៉ែន អីចឹង គាត់ស្លាប់អស់ហើយ តាវ៉ែន អ្នកបញ្ជាខ្ញុំផ្ទាល់ ព្រោះគាត់ថ្នាក់ខាងក្រោម ថា តាឲ្យ ស៊ាន់ ឯងទៅកើតទៅ ព្រោះអត់មានកម្លាំងទេ ចាំទទួលកម្លាំងគេមកពីឥសានហើយនៅជាមួយគេហ្នឹងទៅឯង នៅនេះក៏អត់មានកម្លាំងដែរ គាត់និយាយចេះណាស់ ។

ដានី៖ ចឹងអឹចេញពីត្រាតមកចុះនៅ៨០៨?

ស៊ាន់៖ បាទ!ដឹកមកចុះនៅហ្នឹងតែម្ដង ក៏ដេកនៅគេហ្នឹងទៅ ។

ដានី៖ ចុះមកហ្នឹងបានឃើញ សូរ ហុង នៅហ្នឹង?

ស៊ាន់៖ បាទ! សូរ ហុង គាត់អ្នកទទួលខ្ញុំតើ ។

ដានី៖ មានគ្នាច្រើនទេ នៅ៨០៨ហ្នឹង?

ស៊ាន់៖ មានប្រជាជនរាប់ពាន់ ប្រជាជនដែលរត់មកពីនេះពីនោះ ។

ដានី៖ ៨០៨នៅអូរជ្រៃហ្នឹង?

ស៊ាន់៖ ៨០៨គេហៅភ្នំតាចក់យាយចែមអីហ្នឹងណាស់ កាលហ្នឹងយាយចែម នៅហ្នឹង យាយចែមនៅអន្លង់វែង ។

ដានី៖ ចឹងមិនមែនទៅខាងម៉ាឡៃខាងអី?

ស៊ាន់៖ អត់មានទេ ម៉ាឡៃខ្ញុំមិនដែលស្គាល់ផងអត់ដែលទៅផង ។

ដានី៖ នៅខាងភូមិដូងអីហ្នឹង?

ស៊ាន់៖ អត់ដែលស្គាល់ផង ខ្ញុំមិនដែលទៅទេ ។

ដានី៖ ចឹងចុះមកនៅ៨០៨?

ស៊ាន់៖ មក៨០៨មកតាមភូមិថៃ គេឲ្យពួកខ្មែរក្រហមនៅម៉ាប្រុកមានថៃគេគ្រប់គ្រងចឹង ។

ដានី៖ ហើយដល់ពេលស្នាក់នៅ៨០៨រយៈពេលប៉ុន្មានទៅ?

ស៊ាន់៖ ប្រហែលជាមិនយូរទេ យ៉ាងច្រើន១០ចុះ តា ហុង គាត់បញ្ជាថា ប្អូនឯងទៅកើតវិញ ទៅ ប្អូនទៅកើតទៅ ព្រោះថ្នាក់លើឲ្យទៅខាងមុំបីទទួលកម្លាំង ថៃក៏ដឹកទៅទៀតបានទៅ ជួបលោក កែវ ហ្នឹង ។

ដានី៖ បាទ ។

ស៊ាន់៖ លោក កែវ ហ្នឹងគាត់អ្នកទទួលច្រកខាងហ្នឹង ខ្ញុំក៏មិនស្គាល់ច្បាស់ដែរ គ្រាន់តែសួរថា ខ្ញុំនៅកន្លែងណាបើកន្លែងនេះសុទ្ធតែព្រៃចឹង តែគេទៅទទួលហ្នឹងគេដាក់នៅស្រុកថៃទេ បង កែវ ថា បងឯងចេះតែដើរទៅមុខទៅ ទៅដល់ព្រំដែនទៅយើងនិងឃើញផ្លូវចុះ ហើយខ្ញុំមានក្មេងៗនៅជាមួយគេហ្នឹងគេនាំខ្ញុំមក នាំមកដល់ច្រកហ្នឹងគេហៅច្រក ត្រពាំងគល់ហ្នឹង មានផ្លូវចុះមែន មានផ្លូវចុះទៅក្រោមប្រហែលជាមួយអាទិត្យគេនាំពួក កម្លាំងមក ។

ដានី៖ កម្លាំងជាកងទ័ពឬជាប្រជាជន?

ស៊ាន់៖ កម្លាំងជាកងទ័ព មកពីឥសាន ខ្ញុំសួរថា កម្លាំងនេះមកពីណាគេថាកម្លាំង៨០១ចឹង ហើយបានគេរៀបចំកម្លាំងហ្នឹងឲ្យខ្ញុំមកជាមួយលោក ឃី ហ្នឹងឯង មកនៅកន្លែងហ្នឹងវិញ នៅក្បាលអូរ ៤០គេហៅវាលដងទង់ហ្នឹង ។

ដានី៖ ចឹងក្បាលអូរ៤០ពេលហ្នឹងគេហៅអីវិញទៅ?

ស៊ាន់៖ កន្លែងហ្នឹងគេនៅតែហៅក្បាលអូរ៤០រាល់ថ្ងៃហ្នឹង ។

ដានី៖ ចឹងមកនៅហ្នឹងវិញបានចាប់បង្កើតជាកងពល?

ស៊ាន់៖ បាទ!មកនៅហ្នឹងវិញកងទ័ព៨០១ហ្នឹងគេចាប់ផ្ដើមបង្កើតកងពល៦១២ ។

ដានី៖ តា ម៉ុក គាត់មានដែលមកហ្នឹងវិញឬអត់ទេ?

ស៊ាន់៖ តា ម៉ុក អត់មានមកទេ ។

ដានី៖ តែអ៊ីមានប្រសាសន៍មិញ ពេលអ៊ីមកនៅហ្នឹង តា ម៉ុក គាត់ចាត់ឲ្យអ៊ីមកនៅ?

ស៊ាន់៖ អត់ទេ នៅនោះខ្ញុំនិយាយហួសប្រទ្បាំ មកដល់មុំបីហ្នឹងគាត់មក គាត់មកតែពីរថ្ងៃទេ ហើយគេ បែកទ័ពមកតាមភ្នំដងរែកចឹងមកមួយចំនួននៅហ្នឹងទៅ ហើយឡើងមកជាបន្តបន្ទាប់តាមខ្ញុំដឹង ខ្ញុំមិនបាននៅហ្នឹងទេមាន៤១៧ក៏ឡើងមកហ្នឹងដែរ តាសុន សេន ក៏ឡើងហ្នឹងដែរ ខ្ញុំអត់មាន បាននៅទេ ខ្ញុំមកបាត់ហើយ ។

ដានី៖ ចឹង១០០១ហ្នឹង តាម៉ុក គាត់ទៅដល់មុន សុន សេន ទៀត?

ស៊ាន់៖ មុន ព្រោះតាម៉ុក គាត់ដើរមុនគេ ពីដើមគេប្រើតែ តាម៉ុក ហ្នឹងទេ តាម៉ុក គាត់ ដើរខាងក្រោមៗចឹងណាស់ មិនមែនបញ្ជាយើងផ្ទាល់ទេ មានថ្នាក់ក្រោមគាត់ទៀតជា អ្នករៀបចំ ។

ដានី៖ ចឹងទៅដល់ហ្នឹងចេញ១០០១នៅហ្នឹងទៅ?

ស៊ាន់៖ បាទ! ចេញ១០០១ទៅ ។

ដានី៖ ចឹងចេញពី១០០១មកចេញលេខប៉ុន្មានទៀត?

ស៊ាន់៖ ចេញ១០០១មកហើយចំប្រក១០០២នៅជុំបរុននេះហ្នឹងឯងហើយគេបង្កើតមួយទៀត គេហៅថា កន្លែងដើមត្រាំងដីក្រហមនោះថៃនោះធ្វើមន្ទីរពេទ្យកន្លែង តាមុត អីនៅក៏បង្កើត ១០០៣នៅកន្លែងហ្នឹងមួយទៀត ខ្ញុំដឹងតែប៉ុណ្ណឹងទេ ។

ដានី៖ ចឹងមកដល់ជុំបរុនហ្នឹងបង្កើត១០០២នៅឆ្នាំណាទៅឆ្នាំ៨០ឬមិនមែនទេ?

ស៊ាន់៖ មិនមែនទេ៨០ទេខ្ទង់៨១អីហ្នឹង បើ៨២ខ្ញុំចុះ ខ្ញុំចុះខ្ញុំចេញពីហ្នឹងហើយ ចេញពីជុំបរុន ហ្នឹង ឯង ។

ដានី៖ ចឹងជុំបរុន១០០២ចឹងកាល១០០១នៅកន្លែងដដែល?

ស៊ាន់៖ ១០០១នៅដដែលហើយ១០០២ មកបង្កើតជុំបរុនហ្នឹងនៅខាងលិចជុំបរុនហ្នឹងមាន ១០០៣ ។

ដានី៖ ១០០៣ហ្នឹងបង្កើតដំណាលគ្នាដែរឬមួយយ៉ាងម៉េច?

ស៊ាន់៖ បែបទំនងក្រោយទេខ្ញុំចុះទៅក្រោមហើយ ។

ដានី៖ ចឹងកន្លែង១០០៣កន្លែងមន្ទីរពេទ្យហ្នឹងកន្លែងដីក្រហម?

ស៊ាន់៖ ដីក្រហមដីថៃមិនមែនដីខ្មែរទេ ។

ដានី៖ តែបើជាប់ដីខ្មែរវិញនៅកន្លែងណាទៅ?

ស៊ាន់៖ អូនឯងមានដែលទៅខាងទំនប់ដាច់អត់ ។

ដានី៖ អត់ដែរ ។

ស៊ាន់៖ បើទៅមើលត្រឹមទំនប់ដាច់ក៏ឃើញដែរ ឃើញកន្លែងហ្នឹងមានវិហារដីថៃមួយវាដាក់លើដី ខ្មែរ ហើយមានផ្លូវត្រង់ទៅក្រោយចឹងអាហ្នឹងហើយកន្លែងខ្មែរក្រហមនៅធំជាងគេ ។

ដានី៖ ចឹងកន្លែងប្រកជាំអីហ្នឹងកើតក្រោយ?

ស៊ាន់៖ អូ! អាហ្នឹងកើតក្រោយទេ កើតក្រោយបំផុត ។

ដានី៖ ចឹងក្បាលទន្សោងអី?

ស៊ាន់៖ ហ្នឹងកើតក្រោយមែនតែម្តង កើតប្រហែលខ្ទង់ឆ្នាំ១៩៩៥អិហ្នឹង៩៤-៩៥ហ្នឹង៩៦អីប៉ុណ្ណឹង ។

ដានី៖ ចឹង១០០២ហើយទៅខាង១០០៣ក្រោយ តាមុត អីគាត់នៅហ្នឹង?

ស៊ាន់៖ បាទ ។

ដានី៖ ដល់ហើយក្រោយមក តាម៉ុក គាត់ទៅនៅណាវិញទៅ?

សំាន់៖ ខ្ញុំអត់ដឹងថា ពីណាបង្កើតទេ បើនិយាយថា តាមុត បង្កើតក៏ខ្ញុំមិនចោទគេ ព្រោះអា ហ្នឹងគេហៅលេខចឹងតែម្តង អ្នកបង្កើតខ្ញុំមិនបានដឹងទេ គ្រាន់គេធ្វើផ្លូវចេញពីថៃចឹងទៅ យើងកងទ័ពឬប្រជាជនអី មានសភាពការណ៍អីមិនល្អគេបញ្ជូនទៅហ្នឹង ។

ដានី៖ ចឹងក្រោយមកអ៊ំមកនៅខាងកងពលនេះ អ៊ំចុះទៅខាងទន្លេសាប?

សំាន់៖ បាទ! គ្រាន់តែរៀបចំកងពលគេបញ្ជូនខ្ញុំទៅក្រោមបណ្តោយ ទៅក្រោយមានគ្នា៦០នាក់ ដឹបូងគេថា កម្លាំងស្រាល ។

ដានី៖ ដល់ពេលទៅក្រោមអ៊ំនៅចំណុះកងពល៦១២?

សំាន់៖ បាទ! នៅកងពលជាមួយ តាហឿន ។

ដានី៖ ចឹងអ៊ំមានប្រសាសន៍ក្រោយមកទៀតថា ៦២៦ករាជ្យយ៉ាងម៉េច?

សំាន់៖ ៦២ហ្នឹងកងខ្ញុំចាស់ គេបង្កើតកងពលហ្នឹងមាន៦១មាន៦២មាន៦៣ តែ៦៣ហ្នឹង ក្រោយមកគេដកទៅខាងត្រាតអស់ទៅ ។

ដានី៖ ចឹងម៉ាកងពល៦៣ហ្នឹងដកទៅខេត្តត្រាតអស់ទៅ?

សំាន់៖ បាទ! ចឹងនៅសល់៦២ហើយនៅសល់៦១ជាមួយបងហឿន កងពលហ្នឹងណាស់នៅ សល់៦១ហើយគាត់ចេះតែបំបែកទៅខ្ញុំចុះទៅក្រោមហើយ គេបំបែកគេរៀបកងអីទៀតចឹង ហើយយូរទៅដូចខ្ញុំនិយាយជ្រុលខាងដើមថា បីកុំបីកសាង យើងត្រូវកសាង កម្លាំងហ្នឹងបានទ័ពច្រើនណាស់ បានមួយវរសេនាធំតែម្តងកម្លាំងថ្មី ។

ដានី៖ កម្លាំងរបស់អ៊ំ?

សំាន់៖ បាទ! កម្លាំងចេញពីទាហានខាងរដ្ឋកម្ពុជាហ្នឹង ចេញពីប្រជាជនចេញពីអីមកវាមានទំនាស់ ផ្ទៃក្នុងទៅវាមកនៅជាមួយយើងវាចឹង ។

ដានី៖ អ៊ំទៅនៅខាងទន្លេសាបបានប៉ុន្មានឆ្នាំដែរ?

សំាន់៖ តាំងពីឆ្នាំ១៩៨១ដល់ដើមឆ្នាំ៨៨បានខ្ញុំឡើងមកវិញ ឡើងមកដោយសារឈឺ ឈឺ ហើយគេសែងឡើងមកភ្នំទៅដេកពេទ្យនៅស្រុកថៃនោះ ។

ដានី៖ ចឹងពី៨១ដល់៨៨នៅខាងទន្លេសាបហ្នឹង?

សំាន់៖ បាទ ។

ដានី៖ ចឹងមានទីតាំងច្បាស់លាស់ដែលនៅខាងទន្លេសាបហ្នឹង?

សំាន់៖ អត់មានទេ ។

ដានី៖ នៅក្នុងព្រៃឬក្នុងភូមិ?

សំាន់៖ ខែវស្សានៅក្នុងទឹកខែប្រាំងនៅព្រៃរនាម ទូកលាក់ចឹងកប់វាចឹងទៅ ។

ដានី៖ ចាប់ពីក្រយាលសង្រ្គាមរហូតទៅ?

ស៊ាន់៖ អត់ទេ មិនមែនក្រយាលសង្គ្រាមទេ ចាប់ពីក្រោមស្មោង សង្ក័យនោះ ទៅទន្លេសាបទៅ ទៅកំពង់លែងភ្នំកន្តែបភ្នំអីចឹងទៅណាស់ ខ្ញុំធ្វើការទល់គ្នានិងអ៊ុយម៉ាល់ខ្លាគ្រហឹម ភូមិទួល សំបូរ ។

ដានី៖ ជាមួយ តាផល ដែលឬមួយអត់ទេ?

ស៊ាន់៖ តាផល ណាចេះ ។

ដានី៖ តាផល គាត់ក្រុមប្រឹក្សាស្រុកវាលវែង ឈ្មោះ ឯក សុផល?

ស៊ាន់៖ អត់ទេ មិនមែនទេ បើថា ពួកទៅនោះដាច់ពីខ្ញុំ ខ្ញុំនៅជាមួយកង តាពីម រាល់ថ្ងៃហ្នឹងប្រធានកងពលហ្នឹង តែស្លាប់អស់ហើយខ្មោច ផ្លួន សម្បត្តិអី ពីមុន សម្បត្តិ គាត់ធ្វើប្រធានស្រុកអន្លង់វែងជាមួយលោក សាន នេះ យឹម សាន ហ្នឹងឯង ។

ដានី៖ ចឹងពេលអ៊ំឡើងមកវិញពេលឈឺឆ្នាំ១៩៨៨មកសម្រាកពេទ្យយូរទេ?

ស៊ាន់៖ បាទ!សម្រាកនៅពេទ្យខ្ញុំមិនបានចាំខែទេ បីខែឬបួនខែ ដល់ចឹងទៅមកវិញ មកដល់ថៃវាដឹកមកដឹកចូលកន្លែងតាម៉ុក នៅអន្លង់វែងផ្ទះតាម៉ុក ចាស់ហ្នឹង ។

ដានី៖ ផ្ទះនៅលើភ្នំ?

ស៊ាន់៖ អត់លើភ្នំទេ ផ្ទះនៅខាងក្រោមហើយហ្នឹង ។

ដានី៖ ផ្ទះក្បែរបឹងហ្នឹង?

ស៊ាន់៖ បាទ!ផ្ទះក្បែរបឹងហ្នឹង ។

ដានី៖ អាហ្នឹងឆ្នាំ១៩៩០ហើយ?

ស៊ាន់៖ ឆ្នាំ១៩៩០ហើយ មុនដំបូងដឹកខ្ញុំមកដាក់ដុបរុនទេ ដាក់កន្លែងខ្ញុំផ្ទះខ្ញុំនៅរាល់ថ្ងៃហ្នឹងពីមុនដែលមកនៅនេះ ដល់ខ្ញុំឈឺដឹកទៅវិញ ខ្ញុំមកព្យាបាលពេទ្យមកប្បាបាលថ្នាំខ្មែរអីចឹងទៅណាស់ ឈឺដឹកពេទ្យហ្នឹងវិញ គេទៀមទារឲ្យខ្ញុំកាត់ពោះវៀន គេថាកាត់បានជា បើមិនកាត់មិនជាទេ ហើយខ្ញុំមិនព្រមកាត់ គាត់ថាមិនកាត់ឥឡូវឈប់ធ្វើអីទៅ ទៅនៅព្យាបាលនៅផ្ទះទៅ ។

ដានី៖ ពីណាថាចឹង?

ស៊ាន់៖ តាម៉ុក ចឹញ្ចឹមប្រពន្ធទៅចិញ្ចឹមមាន់ទាអីទៅ ខ្ញុំនៅហ្នឹងរហូតមកដល់ឆ្នាំ៩៤ ខ្ញុំមានកម្លាំងកំហែងស្រួលបួលគេ គេទៅរៀបចំស្រុកត្រពាំងប្រាសាទនេះឲ្យខ្ញុំគ្រប់គ្រង ខ្ញុំធ្វើប្រធានស្រុកហ្នឹងបណ្តោយ អស់ត្រឹមហ្នឹងចប់អត់មានអីទៀតទេ ធ្វើចៅហ្វាយស្រុកបណ្តោះអាសន្នហ្នឹងណាស់ មានចៅហ្វាយស្រុកអន្លង់វែងនិងចៅហ្វាយស្រុកត្រពាំងប្រាសាទមានតែពីរស្រុកហ្នឹងទេ ហើយអ្នកគ្រប់គ្រងឈ្មោះ ផុន តែ ផុន ហ្នឹងវាងាប់ហើយឥឡូវនៅភ្នំពេញនោះ ។

ដានី៖ ឈ្មោះ អី ទឹម ផុន?

ស៊ាន់៖ ឈ្មោះ ខឹម ឌុន អ្នកគ្រប់គ្រងផ្នែកខាងក្រោយនិងណាស់ ។

ដានី៖ ចឹងត្រពាំងប្រាសាទចាប់ផ្តើមកើតឆ្នាំណា?

ស៊ាន់៖ ឆ្នាំ៩៤ ។

ដានី៖ ពីណាគេជាអ្នកបង្កើតកាលហ្នឹង?

ស៊ាន់៖ ទេ កាលហ្នឹងពីណាអ្នកបង្កើតកាលហ្នឹងមាន ០៥នេះ ជាអ្នកចាត់តាំងខ្ញុំ គេហៅ សារឿន ០៥ដែលតាម៉ុក វាយចោលនោះ ព្រោះផ្ទះគាត់និងផ្ទះខ្ញុំនៅជាប់គ្នា កាលនោះ អើនិយាយរំលងបន្តិចដល់ខ្ញុំធ្វើចៅហ្វាយស្រុកនៅហ្នឹងបានប៉ុន្មានឆ្នាំទេ មើល៩៤-៩៥-៩៦ដល់៩៨ ដែលយើងធ្វើសមាហរណ៍កម្មហ្នឹងណាស់ ដែលវាយគ្នាបួនឆ្នាំច្រើនដែរ ជិតបួនឆ្នាំវាមិនមែនដើមអាចចុង ។

ដានី៖ បាទ ។

ស៊ាន់៖ ចឹងហើយវាបែកបាក់គ្នាទៅ ប៉ែកខាងកើតហ្នឹងវាយប៉ែកខាងលិច ។

ដានី៖ ខាងណាខាងកើត?

ស៊ាន់៖ ខាងកើតពួកខ្ញុំនេះឯង ខាងកើតហ្នឹងមិនមែនតាម៉ុក ទេ ០៥វាយកម្លាំងតាម៉ុក ហ្នឹងតែ កម្លាំងតាម៉ុក បែកជាពីរទៀត ពួក តាពឹម ពួក ដាន់ណាអីហ្នឹងគាត់រត់ទៅខាងស្រែណូយ ទៅពួកខ្ញុំរត់ទៅខាងទំនប់ដាច់ទៅ ចូលជាមួយតាឌឹក វាយបកទៅវិញ រឿងហ្នឹងវាចឹង រឿងហ្នឹងអស់ប៉ុណ្ណឹង ដល់វាយចឹងទៅ ពេលតាម៉ុក គាត់ឈ្នះ គាត់ចុះមកវិញបង្រួបបង្រួមគ្នាហ្នឹង គាត់ថាពួកខ្ញុំប៉ែកខាងកើតគាត់យកទៅដាក់នយោបាយមួយឆ្នាំ ដាក់នៅអន្លង់វែងក្រោយផ្ទះសំណាក់គេសព្វថ្ងៃ អត់មានឲ្យមកផ្ទះទេ មានសាលារៀនជាមួយគេរាល់ថ្ងៃចឹងទៅ មាន ជុំ ជាតិ មាន ជា កែវ មាន ពីន រស់ សយ នៅរាល់ថ្ងៃហើយយ៉ោក ជឿន ស្លាប់ហើយនិងមានខ្ញុំនៅទីនោះឯង ។

ដានី៖ មានប៉ុន្មាននាក់?

ស៊ាន់៖ មាន៦នាក់ ។

ដានី៖ មាន ជុំ ជាតិ ជា កែវ មាន ពីន មាន សយ មាន យ៉ោក ជឿន?

ស៊ាន់៖ កាលហ្នឹងមានខ្ញុំនិងវ៉ាន់កុសល្យ តែវ៉ាន់កុសសល្យគាត់មានសំណាងជាងគេ ពួកម៉ាកគាត់លោកគង់ គង់បិញរាល់ថ្ងៃ គាត់ថា អាកុសល្យឯងទៅនៅជាមួយអញ ចាំអញសុំតា មិនដឹងយ៉ាងម៉េចគាត់និយាយគ្នាទៅ ក៏ដកគាត់ទៅនៅខាងហ្នឹងទៅដល់ពេលវាយគ្នាទៅ គាត់ទៅខាងភូណយអីទៅ ពួកខ្ញុំមិនបានទេ នៅខាងនេះរត់ចូលរដ្ឋាភិបាលទាំងអស់ទៅរឿងហ្នឹងចប់ត្រឹមហ្នឹង ។

ដានី៖ ចឹងអឺឆ្នាំ៨៩ដែលយើងចុះមកពីលើភ្នំ ចុះមកអន្លង់វែង ចុះមកខាងនេះមក?

ស៊ាន់៖ មិនមែន៨៩ទេ ឆ្នាំ៩០ ឆ្នាំ៩០ហ្នឹងខ្ញុំមកពីជាំស្វាហើយ មកដល់នៅទីតាំងព្រះប្រឡាយដែលខ្ញុំជិះរាបមិញហ្នឹង ។

ដានី៖ ចឹងជាំស្វានៅក្នុងដីថៃ?

ស៊ាន់៖ បាទ! នៅក្នុងដីថៃ ជិតភូមិថៃ ជិតប្រកខាង១០០២នេះ ។

ដានី៖ ជិតប្រក១០០២?

ស៊ាន់៖ បាទ! នៅពីក្រោយប្រក ។

ដានី៖ ចឹងពេលចុះមកដល់ដំបូងខាងខ្មែរក្រហមមានបង្កើតជាភូមិឃុំស្រុកអីចឹងឬមួយយ៉ាងម៉េច?

ស៊ាន់៖ មិនទាន់បង្កើតទេ ចុះមកហ្នឹងបែកគ្នានៅ ព្រោះវៀតណាមក៏មិនទាន់អស់ដែរ គេគ្រាន់ដកចេញពីព្រំដែនទេ ដាក់ទាហានខ្មែរ ទាហានកម្ពុជានិងទាហានខ្មែរក្រហម បើទាហានខ្មែរក្រហមចុះមកទាហានកម្ពុជាអត់វាយទេ ចេញទៅឯង ចឹងយើងមកនៅហ្នឹងតែម្តង ។

ដានី៖ ចឹងចាប់ផ្តើមបង្កើតជាភូមិជាស្រុកហ្នឹងនៅឆ្នាំ៩៨?

ស៊ាន់៖ ៩៨ហ្នឹងគេរៀបចំខ្ញុំជាចៅហ្វាយស្រុកសូមជំរាបចឹងចុះ ចៅហ្វាយស្រុកហ្នឹងគ្រប់គ្រងអ្នកពិការនិងប្រពន្ធគ្រួសារទ័ពហ្នឹងចឹងទេ ហើយគេចែកចេះមួយវរសេនាធំហ្នឹងគឺមួយឃុំ ។

ដានី៖ ចឹងមួយវរសេនាធំមួយឃុំ?

ស៊ាន់៖ មួយឃុំៗៗយើងបង្កើតចឹងណាស់ សូមទោសមិនមែនមួយវរសេនាធំទេ មួយកងពលមួយឃុំ ចឹងឃុំត្រពាំងប្រាសាទហ្នឹងមានមួយកងពល ។

ដានី៖ ចឹងនៅត្រពាំងប្រាសាទហ្នឹងមានប៉ុន្មានកងពលទៅ?

ស៊ាន់៖ នៅត្រពាំងប្រាសាទនេះមានកងពល៦១២មាន៨០២និង៨០០ប៉ុន្មានទេ ភ្លេចហើយកងតាយន នោះមានបីកងហ្នឹង កង តា កែវ អីហ្នឹង ។

ដានី៖ ចឹង៧៨៥អីទេ?

ស៊ាន់៖ ៧៨៥គេនៅខាងនោះទេ នៅខាងអន្លង់វែង ។

ដានី៖ ចឹង៦១៦នៅខាងអន្លង់វែងដែរ?

ស៊ាន់៖ អូស! ហ្នឹងហើយ៦១៦មួយទៀតហ្នឹងមាន៦១៦ដែរ ខាងលោក ញ៉ែន នោះ ។

ដានី៖ ចឹងខាង៩២០?

ស៊ាន់៖ ៩២០ផ្សេងទេ ដល់ក្រោយមកទៀតគេបញ្ចូលមកខាងឃុំផ្អាវហ្នឹងហើយត្រូវហើយ ចឹងបានខ្ញុំថាចាំខ្លះអត់ខ្លះហ្នឹង ខ្ញុំនិយាយទៅតាមខ្ញុំដឹង ចាំមើល៩២០ហ្នឹងចែកជាពីរ មួយផ្នែកទៅខាងអន្លង់វែងមួយផ្នែកចូលមកឃុំត្រពាំងប្រាសាទ ចែកជាមួយឃុំផ្អាវជាមួយតា ញ៉ែន អីហ្នឹងបានមួយកងពល៩២០មាន៦១២ហ្នឹងមាន៦១៦ហ្នឹងគេបូកចូលគ្នាបង្កើតជាឃុំ៦១២បូកចូលគ្នា

កើតមួយឃុំ ហើយឃុំត្រពាំងប្រាសាទហ្នឹងតែមួយឃុំទេ៨០២ហ្នឹង មានមេមួយតា ឆន នៅកំពង់ធំនេះ កូនចៅគេនៅនេះ ចឹងមួយឃុំ ។

ដានី: បាទ ។

សាន់: ចឹងបានចេះតែបបែកទៅ អូស!មួយទៀត៤១៧មួយទៀត កងតា ជុំ យើងនេះហ្នឹងមួយឃុំដែរ នៅឃុំបាក់អន្លង់រាល់ថ្ងៃអាហ្នឹង៤១៧ ។

ដានី: ចឹងខាងកងជនជាតិ?

សាន់: ជនជាតិមានចំរុះនៅចំរុះ ជនជាតិនៅ១០៥ហ្នឹងនៅខាងខ្ញុំដែរ ជនជាតិហ្នឹងមកពីគ្រប់កន្លែងមក ៩២០ក៏មាន១៦ក៏មាន១២ក៏មាន ។

ដានី: ចឹងចាប់ផ្ដើមបង្កើតជាភូមិឃុំ អ៊ីមានប្រសាសន៍មិញថាឆ្នាំណា?

សាន់: ឆ្នាំ១៩៩៤ ។

ដានី: ចឹងអ៊ីចាប់ផ្ដើមមិនទុកចិត្តគ្នាចាប់ផ្ដើមបែកបាក់គ្នាតាំងពីពេលណាមក មានបែងចែកជាក្រុមរបស់តា ប៉ុល ពត របស់តាម៉ុក អីហ្នឹង?

សាន់: ចាប់បែកបាក់គ្នាមើល៩៤-៩៥-៩៦មើល៩៨ហើយ ចាប់ពី៩៧-៩៨ហ្នឹងមាមបញ្ហាហើយ ។

ដានី: ចឹងអ៊ីមានដឹងពីមូលហេតុអីបានមានការបែកបាក់?

សាន់: អត់ដឹងទេ អត់ដឹងសោះ ហ្នឹងហើយដែលគេចោទប៉ែកខាងលិច ប៉ែកខាងកើតនោះអត់មានដឹងទេ អត់មានដឹងមូលហេតុមកពីអី អាណាដណ្ដើមអំណាចណា តែខ្ញុំដឹងចេះ ដំបូងឡើយគឺថា តាម៉ុក បញ្ជាមកថ្នាក់ក្រោមទេ ហើយថ្នាក់ក្រោមមកកងពលពួកខ្ញុំពួកអីហ្នឹង គេថាឥឡូវតាម៉ុកឲ្យពួកគាត់ទៅជួយខាងប៉ារាកាលនោះ ទៅប៉ៃលិនទៅអីចឹង ដល់ទៅប៉ៃលិនចឹងទៅ គាត់ប្រមូលកម្លាំងខាងកើតទៅប៉ៃលិនខ្លះ ។

ដានី: បាទ ។

សាន់: ចឹងទៅដល់ខាងប៉ៃលិនគេចូលជាមួយខាងរដ្ឋាភិបាលមុនទៅ បកមកវិញបានជាកើតរឿងបែកបាក់សម្លាប់ តាសុន សេន ហ្នឹង ។

ដានី: រឿងយ៉ាងម៉េចបានជាសម្លាប់តាសុន សេន ហ្នឹង?

សាន់: ខ្ញុំអត់ដឹង តែតាមគេនិយាយក្រោយមកគេថាតា សុន សេន ក្បត់ចូលជាមួយ ហ៊ុន សែន មានទាក់ទងជាមួយ ហ៊ុន សែន ចឹង ខ្ញុំដឹងតែប៉ុណ្ណឹងទេ ហើយក៏វាយគ្នាចឹងទៅចែកជាផ្នែកនេះផ្នែកនោះចឹងទៅ ។

ដានី: កាលសម្លាប់តាសុន សេន ហ្នឹងជាបញ្ជារបស់តាប៉ុល ពត ឬបញ្ជារបសលតាម៉ុក?

ស៊ាន់ៈ ខ្ញុំមិនបានដឹងដែរ មិនថាអ្នកណាបញ្ជាអត់ដឹង រឿងវាផ្ដើលឈូ ៩ ហ្នឹងរឿងគេសម្លាប់តាសុន សេន ហ្នឹងហើយ ។

ដានីៈ តែបើតាមខ្ញុំដឹងពីការសួរនាំអ៊ីពូមីងហ្នឹង គាត់ថាក្រុមកម្លាំងតា ០៩ហ្នឹងទៅសម្លាប់?

ស៊ាន់ៈ ព្រោះមិនអាចដឹងទេ ព្រោះចេះ ព្រោះខ្ញុំក៏មានរឿងជាមួយ០៩ហ្នឹងដែរ កម្លាំងខ្ញុំមិននៅជាមួយតា ម៉ុក ។

ដានីៈ បាទ ។

ស៊ាន់ៈ ហើយគេចោទថា០៩ហ្នឹង សម្លាប់តាសុន សេន ហើយខ្ញុំចង់ទៅមើលចេះ ខ្ញុំចង់ទៅមើល គាត់ចោទថាខ្ញុំហ្នឹងចូលដៃចូលជើងជាមួយខាង តាម៉ុក ហ្នឹងបានជាទៅមើលខ្មោចតាសុន សេន ចឹងហើយបានជាមានរឿងចោទប្រកាន់ថា យើងវាក្បត់ចេះក្បត់ចុះដែរហ្នឹង តែជាក់ស្ដែង មានប្រជាជនទាំងអស់គេគាំទ្រខ្ញុំ ខ្ញុំអ្នកមិនបានដឹងរឿងទេ តែខ្ញុំក៏ចង់ដឹងការពិតចឹងដែរ ។

ដានីៈ បាទ ។

ស៊ាន់ៈ តែប៉ុណ្ណឹងទេ ឲ្យខ្ញុំដឹងសាច់រឿងអីមែនទែនអត់ទេ កាលហ្នឹងគេមិនសូវឲ្យដឹងទេ ផ្នែកយោធា ផ្នែករដ្ឋបាលគេមិនឲ្យដឹងទេ បែកជារដ្ឋបាលទៅ ។

ដានីៈ ចឹងអ៊ីបន្ទាប់ពីមានបញ្ហាអីហើយ ក្រោយមកមានការបែកបាក់គ្នាខ្លាំងរហូតដល់ពេលវាយគ្នាទៅ ដល់នេះខាងតាម៉ុក គាត់មិនឈ្នះ មិនចាប់តាប៉ុល ពត ចាប់ តា០៩ ចាប់អីម៉ាគគោក ហ្នឹង អាហ្នឹងមូលហេតុយ៉ាងម៉េចទៅ?

ស៊ាន់ៈ អាហ្នឹងយើងចេញអស់ហើយ យើងបែកគ្នាអស់ហើយ ខ្ញុំក៏បែកដែរ អត់មានបានដឹងរឿងគេ គាត់ទោសអីអត់មានបាននៅទេ ។

ដានីៈ ចឹងកាលហ្នឹងមានកម្លាំងច្រើនដែរ យ៉ាងម៉េចបានវាយចាញ់កម្លាំងតាម៉ុក?

ស៊ាន់ៈ ពីណាចាញ់ ។

ដានីៈ ខាងតា០៩ តា អី?

ស៊ាន់ៈ អត់មានវាយមួយភ្លេចចាញ់ទេ តា០៩ តាម៉ុក ចាប់គាត់ទៅ តាម៉ុក ចាប់តា០៩ មាន កម្លាំងផ្ទុកក្នុង ដូចថាខ្ញុំផ្ទុកក្នុងចឹងខ្ញុំដឹងថា អូនឯងចង់ក្បត់ហើយចាត់តាំងកម្លាំងមកតាមដានរក ចឹងទៅ ដល់ចឹងទៅជួបជាមួយគេអូចឹងទៅ នៅខាងណាៗចឹង កាលហ្នឹងតា ០៩រត់ឡើទៅ៤០ ចាប់បានប្រពន្ធយកទៅឲ្យប្រពន្ធហៅមកថា តា មិនធ្វើអីទេ ចុះមកវិញមក ចុះមកវិញគេចាប់ បណ្ដោយ ដល់គេចាប់០៩ហើយវាផ្ដើលខាងនេះ រត់ប្រញ៉ាយគ្នាអស់ទៅ រត់ហ្នឹងមិនទាន់ចូល មួយណាទេ រត់ហ្នឹងដល់តាម៉ុក មកវិញគាត់បង្កើតសាលាមួយ គាត់ស្រាវជ្រាវថាអ្នកណាដែល

ចូលដៃចូលជើងជាមួយ០៥ ០៦ហ្នឹង គាត់យកទៅដាក់សាលាហើយឲ្យធ្វើពលកម្មចំរាញ់ដើម្បីចាប់ទៅដាក់ទ្រុងទៀតចេះ ចឹងបានកើតគេហៅ៦នាក់ដែលខ្ញុំបានជំរាបមិញនោះ ។

ដានី៖ ចឹង៦នាក់ដែលមានអីដែរ?

ស៊ាន់៖ មានខ្ញុំដែលហ្នឹង មិនមែនឲ្យនៅនេះទេ ហៅហ្នឹងឲ្យទៅនៅអន្លង់វែង ។

ដានី៖ បាទ ។

ស៊ាន់៖ តែដូចថា បុណ្យយើងវាមានខ្លះដែលចង់និយាយចឹង សំណាងយើងវានៅល្អដែរ ទទួលពេលនោះ តាម៉ុក មកប្រកាសក្នុងសាលាហ្នឹង ពួកអាប៉ែកខាងកើតដែលមកប៉ុន្មាននាក់នេះត្រូវយកកូនប្រពន្ធមកធ្វើផ្ទះនៅអន្លង់វែងទាំងអស់ ដល់មានឈ្មោះចឹង ជុំ ជាតិ នេះ ជា កែវ នេះ តាពីន នេះ តាសយ នេះ រាល់ថ្ងៃនេះ តែតាពីន គាត់នៅព្រះវិហារ ចឹងគាត់ប្រជុំគ្នាព្រោះតាជុំ គាត់ធ្វើប្រធាន ហើយតាញ៉ឹន គាត់អ្នកគ្រប់គ្រងសមាសភាពដូចខ្ញុំចឹង គាត់នៅអន្លង់វែងហ្នឹង ដល់ចឹងតាជុំ គាត់មានមតិថាឥឡូវចេះ ឥឡូវឲ្យខ្ញុំឲ្យជឿននៅចាំកន្លែង ខ្ញុំហ្នឹងចង់និយាយគាត់ ខ្ញុំនិងកែវ តាពីន តាសយ ទៅប្រូតស្បូវនៅត្រពាំងប្រាសាទហ្នឹង គាត់មកយប់ហ្នឹង គាត់ចេញទៅយប់ហ្នឹង ហើយខ្ញុំមិនបានដឹងទេ អត់មានបានដឹងថាផែនការគាត់រត់ទេ ចឹងគាត់មកហើយគាត់រត់ទៅ រត់ទៅគេលើកទ័ពតាមតើ តែតាមរកគាត់មិនឃើញ គាត់រត់កាត់ព្រៃស្អាក កាលហ្នឹងព្រៃស្អាកមិនមែនវាលចេះណាណែនប៉ែសព្រៃស្ទុះតែម្តង គាត់រត់កាត់ព្រៃចឹងទៅ ទៅក្បែរភ្នំគូលែនទៅ ទៅជួបជាមួយទាហានរដ្ឋាភិបាលនៅហ្នឹងក៏ចូលជាមួយគេទៅបែបគាត់ទៅជួបជាមួយសម្តេច ហ៊ុន សែន ដឹងបានជិះយន្តហោះមកបាចខិតប័ណ្ណអំពាវនាវឲ្យពួកយើង ថាកុំឲ្យតាម តាម៉ុក អី តាម៉ុក ក្បត់ចេះចុះអីចូលជាមួយរដ្ឋាភិបាលទៅដើម្បីរស់ទាំងអស់គ្នាក៏ពួកខ្ញុំឈូមកបណ្តោយរត់ចេញមកទាំងអស់ ពួកហ្នឹងក៏តាមមកវាយគ្នាឯងដែរ តែកាលហ្នឹងមានយោធាខ្លះគេចាំស្កាត់ រត់ទៅនៅទំបន់ដាច់ ។

ដានី៖ ចឹងមានបានចាំឆ្នាំទេ តាជុំ ជាតិ តាជា កែវ រត់ទៅហើយមកវិញបាចត្រាក់អីចឹង?

ស៊ាន់៖ ខ្ញុំវាពិបាកចាំទៀត?

ដានី៖ ប្រហែលជា៩០ប៉ុន្មាន?

ស៊ាន់៖ ចាំមើលខ្ញុំគិតសិន ខ្ទង់ឆ្នាំ៩៨អីហ្នឹង ឆ្នាំ៩៧-៩៨អីហ្នឹង ចុងហ្នឹង មិនទាន់ចូល៩៩ទេ ព្រោះ៩៩យើងចូលជាមួយរដ្ឋាភិបាលហើយ ។

ដានី៖ ចឹងកាលរត់ហ្នឹងខាងតូ ដាន់ណា គាត់ទៅខាងនោះហើយ?

ស៊ាន់៖ ដាន់ណា គាត់ទៅខាងបៃតាប់ តាពឹម អីហ្នឹង ។

ដានី៖ ចឹងកាលមួយរឹកទៅហ្នឹង តាជុំ ជាតិ តាកែវ អីហ្នឹងមកខាងនេះមក?

សុាន់:   មកខាងនេះ ចូលទៅខាងព្រះវិហារ ខាង ផាន់ណា ចូលទៅខាងសៀមរាបចឹង ។

ដានី:   ចឹង តាម៉ុក ចាប់ប្រពន្ធតា ០៥មកឲ្យគេអូហៅតា០៥មកតា០៦ក៏នៅជាមួយតា០៥ដែរ?

សុាន់:   អត់ទេ នៅខុសគ្នា ។

ដានី:   ចឹងម៉េចបានគេចាប់បានមកជាមួយគ្នា?

សុាន់:   ០៥គាត់មកគាត់ហៅដែរ ថា តា មិនធ្វើអីទេ មកទាំងអស់គ្នាទៅដល់មកគេដាក់ខ្នោះគេដាក់គុកបណ្តោយទៅណាស់វាចឹង ។

ដានី:   ចឹងរឿងនេះវាធំដុំបានជាយកពួកគាត់ទៅសម្លាប់ចោលទាំងអស់?

សុាន់:   រឿងមិនធំយ៉ាងម៉េចយកទៅសម្លាប់ចោលហើយ ហើយសុទ្ធតែជំនិតរបស់គាត់ តាមខ្ញុំដឹង០៥ហ្នឹងជាអន្តរក្សរបស់តាម៉ុក តាំងពីនៅព្រៃសម្ងាត់ណាតាំងពីឆ្នាំ១៩៦៨ណានោះ តាមខ្ញុំឮគេនិយាយណាស់ ។

ដានី:   បាទ ។

សុាន់:   ហឺ!មិនគួរគាត់យកទៅសម្លាប់ចោលវាមិនត្រូវសោះ ។

ដានី:   សម្លាប់កាលហ្នឹងមាន០៥មាន០៦?

សុាន់:   កាលហ្នឹងមាន០៥ មាន០៦ មានតា ឃន ហើយ តាសែន មាន ខេមរា ប៉ុណ្ណឹងឯង ។

ដានី:   មានតា០៦ តាឃន មាន ខេមរា មាន តាសែន មាន៥នាក់?

សុាន់:   បាទ!មាន៥នាក់ មានយាយ នន មួយទៀត ។

ដានី:   ចឹងគាត់ស្រីគេសម្លាប់គាត់ដែរ?

សុាន់:   មិនដឹងកាលហ្នឹងតាមខ្ញុំឮគេនិយាយតៗគ្នាទេ អាហ្នឹងដាក់ស្អែងមិនដាក់ស្អែងខ្ញុំមិនប្រាកដដែរ ថា យាយ នន ហ្នឹងគេឲ្យមកវិញទេ អត់មានទោសពៃរទេ តែគាត់ថាប្តីគាត់ស្លាប់ហើយគាត់លោតចូលក្នុងរណ្តៅហ្នឹងទៅដៃអាអិចហ្នឹងគេសង្កាត់ហើយលុបដីទៅ ហ្នឹងតាមឮគេនិយាយតៗគ្នាចឹង បើមិនដាក់ស្អែងតាមសើុបសួរតទៀតទៅ ។

ដានី:   ចឹងកាលហ្នឹងមានបាចគ្រាក់អីយើងរត់ទៅខាងទំនប់ដាច់?

សុាន់:   បាទ ។

ដានី:   ចឹងឆ្នាំណាដែលយើងចុះមកនៅនេះ?

សុាន់:   ចុះមកនៅនេះឆ្នាំ៩៨ចុងឆ្នាំ មកនៅត្រពាំងប្រាសាទហ្នឹង តាជុំ គេឲ្យគាត់ទៅណាទៅណែគាត់មិនទៅគាត់សុំធ្វើចៅហ្វាយស្រុកនៅហ្នឹង កាលនោះគាត់ធ្វើចៅហ្វាយស្រុក គាត់រៀបចំការិយាល័យបី មានការិយាល័យរដ្ឋាបាល មានការិយាល័យសង្គមកិច្ច មានការិយាល័យសេដ្ឋកិច្ចខ្ញុំទទួលប្រធាន ។

ដានី: ចឹងអ៊ីកាន់ខាងការិយាល័យសេដ្ឋកិច្ច?

សាន់: បាទ!ដំបូងហើយហ្នឹង ។

ដានី: ហើយខាងរដ្ឋបាល?

សាន់: រដ្ឋបាលដូចជា អែម សារិន នេះ លោកខាងសង្គមកិច្ចលោក គឹម សាម៉េត គាត់នៅទួលជិតវត្តខាងត្បូង ។

ដានី: ចឹងតាជុំ គាត់?

សាន់: គាត់ជាចៅហ្វាយស្រុក ។

ដានី: ចឹងកាលហ្នឹងចៅហ្វាយស្រុករងមានពីណាខ្លះកាលហ្នឹង?

សាន់: ចៅហ្វាយស្រុករងមាន យ៉ោក ជឿន មាន អ៊ុង វ៉ែន ទី១ យ៉ោក ជឿន ទី២ មានបីកាលនោះមើល ។

ដានី: ចឹងតា សៅ ថាន នេះ?

សាន់: អត់ទេ ក្រោយទេ តាសៅ ថាន ហ្នឹងគាត់ជាប្រធានសាលាស្រុក សាលាស្រុកយើងហ្នឹងគាត់ទទួលប្រធានសាលាស្រុក ដល់ យ៉ោក ជឿន ស្លាប់ទៅបាន សៅ ថាន ឡើង តាពីនឡើងប្រធានសាលាស្រុកម្តង ប៊ុន ពិន ហើយ វ៉ាន់កុសល្យនិងអនុ ដល់ក្រោយមកលោកវ៉ាន់កុសល្យ ដូចថាគីរិះវិជ្ជាគាត់ខ្ពស់ហើយគាត់មានបទពិសោធន៍ច្រើន ហើយគាត់ធ្លាប់ធ្វើមេកងពលចេះចុះផង ក៏ថ្នាក់លើស្រាវជ្រាវដូចជាក្នុយមកចឹងក៏ចាត់តាំងឲ្យគាត់ធ្វើជាចៅហ្វាយស្រុកពេលប្រជុំឡើងទៅខេត្ត ។

ដានី: ឆ្នាំណាហ្នឹង?

សាន់: មិនបានចាំឆ្នាំទេ បន្តបន្ទាប់ ។

ដានី: ចឹងដល់ពេលលោក វ៉ានកុសល្យ ឡើងជាអភិបាលស្រុក ចឹងកាលហ្នឹងអភិបាលរងនៅដដែលឬក៏មានការផ្លាស់ប្តូរដែរ?

សាន់: អត់ទេ អភិបាលរងហ្នឹងនៅតែ អ៊ុង វ៉ែន ដដែល ។

ដានី: បាទ ។

សាន់: ហើយបានឡើង សៅ ថាន ហើយបានឡើង ប៊ុន ពិន មកបានឡើង គឹម សាម៉េត អែម សារិន អ៊ីមកហើយខ្ញុំឡើងត្រឹមអនុប្រធានមន្ទីរទេ កាលនោះ អត់មានបានប្រធានអីនិងគេទេ រហូតមកទល់សព្វថ្ងៃទៅខ្ញុំចូលនិវត្តខ្ញុំនៅត្រឹមអនុប្រធានមន្ទីរទេ ។

ដានី: ចឹងក្រុមប្រឹក្សាស្រុកមានពីរអាណាត់?

សាន់: ទើបទី១ ។

ដានី: ទើបអាណាត់ហ្នឹងទេ?

ស៊ាន់: បាទ!មិនទាន់អស់ អស់ប្រហែលជាខែ៧ ចឹងបានខ្ញុំថាចាស់ហើយខ្ញុំសុំឈប់ធ្វើហើយ តែដល់ឯកឧត្តម សរ ថាវី ហ្នឹងគាត់ថា គាត់ធ្វើតទៅទៀតទៅនៅមានកម្លាំងទេ មិនទាន់ចាស់ប៉ុន្មានទេ មានពិបាកអីក្រុមប្រឹក្សាស្រុកនោះ មួយខែប្រជុំម្តងពីរម្តងនោះ គាត់ចេះតែនិយាយចឹង ឲ្យពីណាធ្វើសុទ្ធតែក្មេងៗចឹង អ្នកណាជួយសម្រេចអីៗសុទ្ធតែក្មេងចឹង ក្មេងទាំងអស់មែន តាំងចៅហ្វាយស្រុករងស្អីៗមន្ទីរអីទាំងអស់ ។

ដានី: ចឹងឥឡូវសុទ្ធក្មេងៗ ?

ស៊ាន់: ឥឡូវសុទ្ធក្មេងទាំងអស់តែម្តង ។

ដានី: យ៉ាងម៉េចបានគេដាក់ក្មេង ចាស់ៗយ៉ាងម៉េច?

ស៊ាន់: ចាស់ៗចូលនិវត្តអស់ហើយក្តួយ ចាស់អស់ហើយវាអស់អាយុហើយមិនអាចធ្វើខាងរដ្ឋបាលបានទេ ដូច្នេះវាមានតែខាងក្រុមប្រឹក្សា ។

ដានី: ចឹងអីសុំបន្តិចទៀតទេ ទាក់ទងពី១០០១-១០០២ បាត់តាំងពីពេលណាទៅ?

ស៊ាន់: ១០០១-១០០២ រលាយកាលខ្ញុំចុះទៅខាងទន្លេសាប ។

ដានី: កាលចុះទៅទន្លេសាប?

ស៊ាន់: មើលឆ្នាំ មើលមិនមែនចុះទៅទន្លេសាបទេ ចាប់រលាយឆ្នាំ១៩៩០ ក្រោយយួនដកពីស្រុកយើង ពេលយួនដកទ័ពទៅចាប់អស់បណ្តើរៗហើយ គេទុកកម្លាំងតិចតួចទៅគ្មានប្រេកទេ ព្រោះប្រេកស្បៀងអាហារអីគេច្រើនយកពីក្រោម ព្រោះយើងមានទំនាក់ទំនងជាមួយប្រជាជនបានហើយណា យើងទិញដូរពីក្រោមចឹងទៅ លែងយកពីតាមថៃហើយ ហើយថៃក៏វារុញយើងបណ្តើរៗ ។

ដានី: ចឹង១០០១-១០០២រលាយ នៅសល់១០០៣មួយទេឬរលាយទាំងអស់?

ស៊ាន់: ១០០៣ហ្នឹងក៏អត់មានដែរ ១០០៣ហ្នឹងគេបូកមកវាមានពីរប្រេក ខ្ញុំនិយាយប៉ែកខាងកើតមិននិយាយពីខាងលិចទេ ប្រេកសំខាន់នៅជាប់រហូតមកវាមានតែពីរទេ ប្រេកជាំអន្លង់វែងយើងនេះ ហើយនិងស្មាច់ ក្រៅពីនោះអស់ហើយ អាហ្នឹងនៅមានប្រេកចេញចូលតែប៉ុណ្ណឹងទេ អូ! មានប្រេកអានសេះមួយទៀត អានសេះខាងជាំក្សាន្ត តែអត់មានឈ្មោះ ១០០១-១០០២-១០០៣អីទៀតទេលុបបាត់តែម្តង ។

ដានី: ចឹងប្រេកអានសេះហ្នឹងកាលពីមុននៅក្នុង១០០០ប៉ុន្មានទៅ?

ស៊ាន់: អាហ្នឹងអត់មានឈ្មោះទេ នៅក្នុង១០០១ មកពីមុំបីមក ។

ដានី: ចឹងមិនមែន១០០២ទេ?

ស៊ាន់៖ អត់ទេ ១០០២មានមួយប្រកនេះ ប្រកជុបរុននេះណាស់ ។

ដានី៖ ចឹងប្រកជុបរុនហ្នឹងមានគេចេញចូលដែលអត់?

ស៊ាន់៖ ជុបរុនមានតែប៉ូលីសយើងទៅនៅ ។

ដានី៖ ចឹងមានតែជាំទេ?

ស៊ាន់៖ មានតែជាំទេចេញចូលគេបើកផ្សារបើកកាស៊ីណូអី ។

ដានី៖ ខ្ញុំនៅតែមានចម្ងល់ថា មិនដឹងជាមានរឿងហេតុអីដែលបណ្ដាលឲ្យមានការបែកបាក់គ្នាខាងកម្លាំងខាងខ្មែរក្រហមហ្នឹង តាមយោបល់អ៊ំ អ៊ំយល់ឃើញថាយ៉ាងម៉េច?

ស៊ាន់៖ ខ្ញុំអត់ឆ្ងល់ទេ មកពីអំណាច ដណ្ដើមអំណាចវាយ ប៉ុល ពត ចោលទៅ ដើម្បីតាម៉ុក ឡើងធ្វើអធិរាជ្យចឹងទៅ ចង់និយាយចឹង ព្រោះកាលនោះគាត់ទោសវាយ ប៉ុល ពត ហើយសូម្បីតែតាៗ ដូចជាតានួន ជា តាខៀវ សំផន តា ស្អីៗទាំងអស់ហ្នឹងខ្លាចតាម៉ុក ទាំងអស់ តាម៉ុកគាត់ប្រើអំណាចខាងយោធា ហើយអ្នកអស់នោះភាគច្រើនខាងនយោបាយហើយ គាត់មានយោធាអី គាត់មានដែលច្បាំងអីគាត់ បើតាម៉ុក មេទ័ពចំតែម្ដងវាចេះ ចឹងវា អំណាចរឿងដណ្ដើមអំណាចញូសញ្ជូង និយាយទៅចេះតែបែកៗណាស់ រឿង ខឹម នុន ហ្នឹង ខ្លាំងជាងគេ ខឹម នុន ខឹម តេម អាដើងពីរនិងគឺខ្លាំងតែម្ដង អ្នកទាក់ទងជាមួយសម្ដេច ហ៊ុន សែន មុនគេ គ្រាន់តែខាងប៉ៃលិនផ្ដាច់ភ្លាមលោក អ៊ី ឈាន គាត់ចូលភ្លាមអីនេះគោងជាប់គោងជាប់ចោទថា ប៉ុល ពត ជាមេកន្ទ្រាញទាល់តែកំទេចចោលបានតាម៉ុក បានឡើងមេការពិតត្រូវតែកំទេចតាម៉ុក ទៀត ។

ដានី៖ ចឹងតាខឹម នុន គាត់មានគំរោងចង់កំទេចតាម៉ុក ទៀត?

ស៊ាន់៖ ទាំងអស់ គាត់ចង់ធ្វើមេដែរ ចឹងបានខ្ញុំថា មូលហេតុមកពីដណ្ដើមអំណាច ព្រោះចេះតាមខ្ញុំវិភាគ ខ្ញុំចេះថា ហ៊ុន សែន ហេង សំរិន ពីមុនមនុស្សតែមួយមានមនុស្សពីរបីណាទ័ពតែមួយទេ ហេតុម៉េចក៏ឈ្លួសគ្នាខ្លះចូលឃ្លួនទៅខ្លះចូលចិនទៅធ្វើឲ្យរាស្ត្រស្លាប់វេទនាមិនដឹងអី ខ្ញុំនិយាយជាក់ស្ដែងពួកខ្ញុំដឹងថាមកធ្វើចឹងវាល្អហើយ ចុះសីលធម៌១២ប្រការរបស់កងទ័ពនោះកូនប្រពន្ធគេ ម្ជុលមួយគ្រាប់ម្ទុលមួយដើម ស្អីក៏ដោយចេមួយសរសៃមិនយករបស់គេទេ អ្នកដែលធ្វើល្អគឺមិនងាយងាប់ទេ តែធ្វើមិនល្អមិនសូវនៅទេ ទៅចឹងតែម្ដងខ្ញុំមើលទេខ្ញុំនិយាយពីបុណ្យបាប ។

ដានី៖ ចឹងបើតាមប្រសាសន៍របស់អ៊ំ ខឹម នុន ខឹម តេម អីហ្នឹងគាត់បើសិនជាអស់ពី ប៉ុល ពត តាម៉ុក ទៅគាត់ធំជាងគេ?

សាន់៖ បាទ!ចុះបើគាត់វាយគេចោលមេៗអស់ហើយ០៥ ០៦ មានពីណាទៀតដែលជាមេកន្ទ្រាញធំៗ ហើយ តាមុត យើងមិននិយាយទេ គាត់ប៉ែកខាងលិចៗ

ដានី៖ ចឹងអឹមានប្រសាសន៍មិញថា ខឹម នុន គេចាត់តាំងឲ្យគ្រប់គ្រងផ្នែកខាងគុក?

សាន់៖ គ្រប់គ្រងផ្នែកខាងក្រោយ ឧទាហរណ៍ថា ខឹម នុន ហ្នឹងគេទៅជាខេត្តហើយតាមមើលណា ទៅជាខេត្តអន្លង់វែងហើយតាមខ្ទុំវិភាគទេ គេអត់មានប្រកាសទេ គាត់គ្រប់គ្រងប៉ែកខាងក្រោយកម្លាំងខាងក្រោយទាំងអស់មានប៉ុន្មានគឺ ខឹម នុន ទទួលៗ

ដានី៖ ចឹងកាលមុនហ្នឹងគាត់មានកាន់ខាងកងពលអីគេទេ?

សាន់៖ អត់ទេ គាត់មានកាន់កងស្ពៃទៅចិន ខ្ញុំដឹងប្រវត្តិ គាត់ទៅចិនគាត់ទៅរៀនខាងបច្ចេកទេសច្រើនចឹងទៅណាស់ ដល់មកវិញដឹងគាត់សឹយ៉ាងម៉េច គាត់បេះខ្លាំងទៅ គាត់ចង់ដណ្តើមអំណាចដែរៗ

ដានី៖ គាត់ចង់បានធំជាងគេ?

សាន់៖ បាទៗ

ដានី៖ ចឹងបើតាមអឹមានប្រសាសន៍មិញអាហ្នឹងជាល្បិចរបស់លោក ខឹម នុន និង ខឹម តេម ធ្វើល្បិចយ៉ាងម៉េចឲ្យខាងលើឈ្លសគ្នា?

សាន់៖ បាទៗ

ដានី៖ ដល់ពេលនេះទៅ ស្លាប់អស់ទៅថ្ងៃក្រោយគាត់ធ្វើធំ?

សាន់៖ ត្រូវហើយ គាត់ចូលទៅជាមួយរដ្ឋាភិបាលទៅមិនរដ្ឋាភិបាលឲ្យអំណាចមកគាត់និងគាត់មិនត្រូវគ្រប់គ្រងប៉ែកព្រំដែននិងមិនអំណាចមួយ គាត់ចង់ធ្វើអីក៏បានដែរៗ

ដានី៖ ចឹងក្រុមរបស់អឹវិភាគទៅចេញចឹង?

សាន់៖ ខ្ញុំគិតគ្នាទៅឃើញចឹងតែម្តង ដែលយើងធ្វើឲ្យអន្តរាយបែកបាក់ៗ

ដានី៖ ចឹងមិនមែនតា ប៉ុល ពត និង តាម៉ុក ជាអ្នកផ្តើមគំនិត?

សាន់៖ អត់ទេ អត់ដឹងទេ គាត់នៅតែជាមួយគ្នានោះ តាម៉ុក តាប៉ុល ពត តានួន ជា នៅជាមួយគ្នាទេៗ

ដានី៖ ចឹងយ៉ាងម៉េចបានជាគាត់ឈ្លសគ្នាបើគាត់នៅជាមួយគ្នា?

សាន់៖ អាហ្នឹងហើយបានខ្ញុំថា មួលក្បាលខ្ទិចកន្ទុយសង្កាលឲ្យខាំគ្នាៗ

ដានី៖ ចឹងរឿងហ្នឹងស្មុគស្មាញដែរ?

សាន់៖ រឿងហ្នឹងវេទនាណាស់ៗ

ដានី៖ ចឹងចុះថ្ងៃក្រោយបានជាគេចាប់គាត់ ខឹម នុន ចាប់គាត់ទៅដាក់គុកនៅភ្នំពេញ?

ស៊ាន់៖ អត់មានចាប់ទេ គាត់ទៅនៅភ្នំពេញតើ គាត់ទៅនៅភ្នំពេញដូចជាពាក់សក្តិ៥កាលហ្នឹង កាលហ្នឹងសក្តិធំមិនទាន់ដល់ផ្កាយទេ តែបើគេពិនិត្យស្រាវជ្រាវឃើញចិនទៅមិនដឹងថាគេចាប់ឬមិនចាប់ទេ គ្រាន់ដឹងថាស្លាប់ ។

ដានី៖ គាត់ជាប់គុកតើ ទាក់ទងរឿងសម្លាប់ជនបរទេស?

ស៊ាន់៖ អូ!ចិន ។

ដានី៖ គាត់ជាប់គុកតើ?

ស៊ាន់៖ ទេ ទាល់ដូចក្មួយស្រាវជ្រាវចិនបានដឹងខ្ញុំអត់បានដឹង ។

ដានី៖ ហើយមានមួយទៀតជាមួយឈ្មោះ ម៉ៅ ។

ស៊ាន់៖ អូ!តាម៉ៅ សក់សដឹង តាម៉ៅ នៅទេរាល់ថ្ងៃ ។

ដានី៖ ខ្ញុំដឹងដែលគេកាលពីលើកមុនគេចាប់គាត់ដោយសារតែគាត់សម្លាប់បរទេស កាលមានបាញ់យន្តហោះអីហ្នឹង?

ស៊ាន់៖ អ៊ូ!មែន ហ្នឹងហើយ យន្តហោះមិនបាញ់ផាប់ចៅហ្វាយខេត្តមួយ ។

ដានី៖ បាទ ។

ស៊ាន់៖ ហ្នឹងហើយបាញ់គ្នាតាំងពីហ្នឹងមក មានឈ្លូសគ្នាជាមួយ០៥អីតាំងពីហ្នឹងមក គេបាញ់សោះចោទ០៥ថាបាញ់ចិន តែពួកហ្នឹងឯងជាអ្នកបាញ់នោះ ។

ដានី៖ ចិនជាល្បិចរបស់គេ?

ស៊ាន់៖ ជាល្បិច ពិភពលោកគេនិយាយតែចិនឯង ។

ដានី៖ ចិនសួរទាក់ទងនិងប្រាសាទព្រះវិហារ កាលហ្នឹងខាងកងទ័ពខាងខ្មែរក្រហមហ្នឹងមិនគ្រប់គ្រងខាងប្រាសាទព្រះវិហារ មានផ្ទះក្រហម?

ស៊ាន់៖ ផ្ទះក្រហមហ្នឹងថៃ ។

វណ្ណៈ៖ ផ្ទះក្រហមកាលពីមុនមកឮថា តាម៉ុក គាត់សាងសង់សម្រាប់គាត់ស្នាក់នៅជាឈើទេ ថាក្រោយមកខាងថៃធ្វើជាថ្មវិញ តាមសំភាសខ្លះជួបចិន តែអ៊ំមានបានដឹងរឿងផ្ទះក្រហមនិងទេអ៊ំ?

ស៊ាន់៖ មិនបានដឹងទេ កាលខ្មែរក្រហមវាយយកឆ្នាំប៉ុន្មានទេ ខ្ញុំមិនបានចាំ ខ្ញុំក៏បានឡើងទៅដែរ ឡើងទៅគេឲ្យខ្ញុំទៅយាមទៀតវាយហើយ ខ្ញុំទៅយាមកន្លែងហ្នឹង ឃើញតែផ្ទះក្រហមថៃដដែល ថៃវាបើកច្រកហ្នឹងដើម្បីភ្ញៀវវាចូលមកប្រាសាទព្រះវិហារនិងវាយកលុយខាងក្រោម ចុះពីនាគយើងទៅ គេហៅចុះនាគទៅដល់មានស្ពានឈើមួយថ្មជាថៃផុត គេធ្វើស្ពានឈើឆ្លងថ្មទេ អានេះ

យើងអានោះថៃ ខ្ញុំដឹងច្បាស់ហើយផ្ទះក្រហមហ្នឹងខ្ញុំធ្លាប់ទៅមើលដែរ ថៃវាសង់អត់មានយើងទេ ។

ដានី: ចឹងកាលពីសម័យសង្គ្រាមក៏ថៃដែរ កាលយើងដាក់ចូលគ្នាយកលុយ ចឹងកាលសម័យយកលុយហ្នឹង កាលជំនាន់លោក ជា សុផារ៉ា ទេ ចង់និយាយថា មុនសមាហរណ៍កម្មទៀត ថាតើខាងតាម៉ុក គាត់ឈរជើងនៅហ្នឹងដែរឬក៏ថៃនៅម្តុំផ្ទះក្រហមហ្នឹង?

ស៊ាន់: ថៃគេនៅតើ មានតែថៃទេ អត់មាន តាម៉ុក ទេ និងជាដីរបស់ថៃតែម្តង ។

ដានី: នៅកន្លែងពយហ្នឹង?

ស៊ាន់: បាទ ។

ដានី: ចឹងផ្លូវចុះមកពីផ្ទះក្រហមហ្នឹងមានដឹងថា ថៃកសាងតាំងពីពេលណាដែរ ផ្លូវចុះពីផ្ទះក្រហមមកដល់ជើងប្រាសាទយើងហ្នឹង មានដឹងថាថៃសាងសង់ពេលណាដើម្បីឲ្យភ្ញៀវចូលទស្សនាតាមហ្នឹងនោះ?

ស៊ាន់: កាលពិតពីមុនអត់មានទេ វាកសាងផ្លូវត្រឹមបន្ទាយវា បន្ទាយវានៅក្រោយផ្ទះក្រហមនៅពីខាងជើងផ្ទះក្រហម ។

ដានី: ចឹងមានត្រឹមហ្នឹង?

ស៊ាន់: បាទ!មានតែត្រឹមហ្នឹងទេ ហើយដល់ក្រោយមកវាចេះតែចាក់កៅស៊ូ កាលមុនជាថ្មដាទេ ។

ដានី: ចឹងថៃចាក់កៅស៊ូប្រហែលជាឆ្នាំណាបើតាមអ៊ំដឹង?

ស៊ាន់: ខ្ញុំមិនបានចាំទាំងអស់ទេ ខ្ញុំមិនបានចាំឆ្នាំគេធ្វើ តែក្រោយយើងវាយរំដោះព្រះវិហារមិនទាន់ធ្វើទេ នៅទេប្រហែលជាឆ្នាំ១៩៩៣ហ្នឹងហើយ៩៣ហ្នឹងវាយរំដោះព្រះវិហារបានពីរដ្ឋាភិបាល ព្រោះចេះកូនខ្ញុំមីពៅហ្នឹងកើតឆ្នាំ១៩៩៣ ពេលវាកើតនៅជុបរុនហ្នឹង ខ្ញុំគេឲ្យទៅយាមប្រាសាទ គេយកអ្នកក្រោយហ្នឹងទៅយាមប្រាសាទ ខ្ញុំទៅយាមប្រាសាទជាមួយ យឹម ដាន អីហ្នឹង ជាមួយគ្នា ។

ដានី: ឆ្នាំ១៩៩៣ហ្នឹង?

ស៊ាន់: បាទ!៩៣ហ្នឹងហើយថៃយើងទៅលេងជាមួយគ្នាអត់មានអីទេ កាលនៅទំនាក់ទំនងគ្នាជិះឡានទៅខេត្តតាឡាក់អីបាន ។

ដានី: ចឹងកាល៩៣យើងវាយយកបានពីរដ្ឋាភិបាលមក យើងឡើងទៅប្រាសាទហ្នឹងហើយថៃនៅណា?

ស៊ាន់: ថៃវានៅផ្ទះក្រហមក្រោយផ្ទះក្រហមហ្នឹងហើយទាហានវា ផ្ទះក្រហមយើងមើលឃើញហ្នឹង ។

ដានី: ចឹងនៅវាលឥន្ទ្រីអីមានថៃទេ?

សាន់៖ អត់មានទេ អត់មានសោះ ទើបមានពេលគេវាយគ្នាឆ្នាំឥឡូវៗហ្នឹងឆ្នាំ២០០៨ហ្នឹង ។

ដានី៖ ចឹងកាលឆ្នាំ៩៣មានតែយើងនៅលើប្រាសាទហ្នឹង?

សាន់៖ មានតែយើង ។

ដានី៖ ចឹងវត្តកែវសិរីស្វារៈ?

សាន់៖ វត្តកែវសិរីស្វារៈអត់មានវត្តទេ មានតែថ្មដា ។

ដានី៖ ចឹងកាលយើងនៅហ្នឹងថៃមានមករករឿងទេ?

សាន់៖ ដើរមកលេងជាមួយគ្នាធម្មតា ។

ដានី៖ ចឹងអត់មានឈរជើងបានទេ?

សាន់៖ អត់ទេ ។

ដានី៖ នៅកន្លែងវត្តហ្នឹង?

សាន់៖ អត់មានទេ ។

ដានី៖ ចឹងវត្តហ្នឹងកើតឆ្នាំណាចឹង?

សាន់៖ វត្តហ្នឹងកើតមកក្រោយហើយទេ កើតឆ្នាំ៩៨នេះ អះ!ឆ្នាំ២០០៨នេះ ។

ដានី៖ ចឹងឆ្នាំ២០០៨?

សាន់៖ បាទ ។

ដានី៖ ចឹងផ្លូវអីទៅឆ្នាំ៩៣ហ្នឹងផ្លូវកៅស៊ូមានចុះមកដល់ខាងក្រោមហើយនៅ?

សាន់៖ អត់មានទេ យើងក៏អត់មានដែរ យើងឡើងតាមព្រៃតើ អត់មានផ្លូវទេ ឆ្នាំ៩៤-៩៥ហ្នឹងបានតាម៉ុក គាត់ឈូស ។

ដានី៖ ឈូសទៅដល់ណា?

សាន់៖ ឈូសដល់វត្តកែវសិរីស្វារៈ កាលហ្នឹងឈូសវាអត់ល្អទេ គ្រាន់តែឈូសជាហេតុៗ ។

ដានី៖ ចឹងកាលឈូសហ្នឹងខាងថៃអត់មានតវ៉ាអីទេ?

សាន់៖ អត់មាន ។

ដានី៖ ចឹងក្រោយមកខាងរដ្ឋាភិបាលយើងឈូសវាតវ៉ា?

សាន់៖ កាលនោះតាម៉ុក ឲ្យលុយ ហើយថៃដឹងថារដ្ឋាភិបាលមិនអាចឈ្នះតាម៉ុក បានទេ ហើយតាម៉ុកដួលដីដាក់ទ័ពដាក់អីនៅហ្នឹង ដល់ក្រោយមកអស់តាម៉ុក អីទៅយើងរួបរួមគ្នាជាមួយរដ្ឋាភិបាលទៅវាចាប់ផ្ដើមបណ្ដោយ ។

ដានី៖ ចាប់ផ្ដើមទន្ទ្រានចូល?

សាន់៖ បាទ!ចាប់ផ្តើមទន្រ្ទានចូល ដូចជាវាលឥន្រ្ទីអីចឹងហើយវត្តកែវសិរិស្មារៈអីហ្នឹងសុទ្ធតែដីយើងទាំងអស់ហ្នឹង ។

ដានី៖ ចឹងប្រាសាទតា មន្តអីហ្នឹង?

សាន់៖ ខ្ញុំអត់ស្គាល់ទេ ខ្ញុំមិនដែលទៅខាងហ្នឹង ចឹងខ្ញុំអរគុណហើយ ។

ដានី៖ បាទ!ខ្ញុំអរគុណអ៊ំច្រើន ដែលបានចំណាយពេលដល់មានតម្លៃទាក់ទងនិងបទពិសោធន៍ដែលអ៊ំធ្លាប់ឆ្លងកាត់កន្លងមក ចឹងអរគុណច្រើន ។

សាន់៖ បាទ!អរគុណ ។

**ចប់**